ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយ ការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ នៅខេត្តស្វាយរៀង

PERSPECTIVES OF TEACHERS AND ACCELERATED TEACHERS

AFTER TRAINING AT NATIONAL INSTITUTE OF EDUCATION

IN SVAY RIENG PROVINCE

ដោយ/by

ឡាច ផាស់ / LACH PHORS

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


## និក្ខេបបទ

# ទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយ ការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ នៅខេត្តស្វាយរៀង

PERSPECTIVES OF EDUCATORS AND ACCELERATED TEACHERS

AFTER TRAINING AT NATIONAL INSTITUTE OF EDUCATION

IN SVAY RIENG PROVINCE


ដោយ/by

ឡាច ផាស់ / LACH PHORS


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២០

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំ**» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះមិនដែលបានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាន និងសាកលវិទ្យាល័យណាមួយឡើយ។ សេចក្តីដកស្រង់ និងខ្លឹមសារផ្សេងៗ ដែលបានយកមកប្រើប្រាស់នៅក្នុងអត្ថបទស្រាវជ្រាវនេះសុទ្ធតែបានចុះបញ្ជីក្នុងឯកសារយោងទាំងអស់។

និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃសៅរ៍ ៨កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០២០

ហត្ថលេខាបេក្ខជន

**ឡាច តាស់**

# លិខិតបញ្ជាក់

លោក **ចាប រតនា** គ្រូដឹកនាំបង្គោល

បណ្ឌិត **នួន វីរ៉ា** គ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ឡាច នាស់** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ នៅខេត្តស្វាយរៀង**» ពិតប្រាកដមែន។

ថ្ងៃសៅរ៍ ៨កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០២០

................................ ...............................

**លោក ចាប រតនា** **បណ្ឌិត នួន វីរ៉ា**

អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ នាយករង

វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៧៣៧ **អយក.ខុទ**

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្ដមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្ដម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ៅ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្ដម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ច័ន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្ដមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# លិខិតថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវមួយនេះ អាចសម្រេចដល់គោលដៅប្រកបដោយភាពជោគជ័យ គឺ ដោយសារមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធនានា ដែលបានចូលរួមផ្តល់ឱកាស ជួយសម្របសម្រួល និងជ្រោមជ្រែងតាំងពីដើមរហូតដល់ចប់។ ហេតុនេះខ្ញុំបាទដែលជាអ្នកសិក្សាស្រាវជ្រាវ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មាន ឧបត្ថម្ភ គាំទ្រ និងផ្តល់ឱកាសឱ្យខ្ញុំបានរៀនសូត្រ ទទួលបានផ្លែផ្កាដូចសព្វថ្ងៃនេះ។

ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ឱ្យខ្ញុំបាទមានឱកាសបន្តការសិក្សានៅទីនេះ។

គណៈគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលា បង្ហាត់បង្រៀនដល់ខ្ញុំបាទដោយមិនគិតពីការនឿយហត់។

សាស្ត្រាចារ្យ **ចាប រតនា** ជាសាស្ត្រាចារ្យដឹកនាំបង្គោល ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃក្នុងការផ្តល់គំនិតណែនាំជាទ្រឹស្តីល្អៗ កែលម្អចំណុចខ្វះខាត ឃ្លាប្រយោគ អក្ខរាវិរុទ្ធ និងផ្តល់កម្លាំងចិត្ត បច្ចេកទេស វិធីសាស្ត្រនានា មិនតែប៉ុណ្ណោះ សាស្ត្រាចារ្យ បានផ្តល់ជាឯកសារដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅដល់រូបខ្ញុំហូតការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យជាស្ថាពរ។

លោកបណ្ឌិត **នួន ទីរ៉ា** ជាសាស្ត្រាចារ្យដឹកនាំរងដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃក្នុងការកែសម្រួល រចនាបទ ឃ្លាប្រយោគ និងរបៀបសរសេរនិក្ខេបបទ ព្រមទាំងជួយកែសម្រួលកម្រងសំណួរផ្សេងៗដែលទាក់ទងនឹងប្រធានបទ និងការវិភាគទិន្នន័យផងដែរ។

មិត្តរួមថ្នាក់ជំនាន់ ទី៧ ទាំងអស់ដែលតែងតែផ្តល់កម្លាំងចិត្តដល់រូបខ្ញុំបាទ តាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យខ្ញុំបាទមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក

និងឧបសគ្គទាំងឡាយដើម្បីសម្រេចគោលដៅនៃការស្រាវជ្រាវសរសេរនិក្ខេបបទនេះ។

គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកពាក់ព័ន្ធ ទាំងអស់ដែលបានចូលរួមឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការផ្ដល់ទិន្នន័យធ្វើឱ្យការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យ។

ជាទីបញ្ចប់នេះខ្ញុំបាទសូមគោរពជូនពរ ដល់អ្នកមានគុណទាំងទ្វេ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអង្គការដៃគូអភិវឌ្ឍ ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមជួបប្រទះតែសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់ប្រការ មានសុខភាពល្អបរិបូណ៌ សម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងឡាយ ៤ប្រការគឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ..... ii

លិខិតបញ្ជាក់..... iii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ..... iv

លិខិតថ្លែងអំណរគុណ ..... v

មាតិការ ..... vii

បញ្ជីតារាង ..... xi

បញ្ជីរូបភាព..... xiii

មូលន័យសង្ខេប ..... xiv

ជំពូកទី១ សេចក្តីផ្តើម ..... ២

១.១. លក្ខណៈប្រជាសាស្ត្រ និងភូមិសាស្ត្រ ..... ២

១.២. លំនាំបញ្ហា..... ៣

១.៣. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ៥

១.៤. គោលបំណងនៃការស្រាវជ្រាវ ..... ៦

១.៥. សំណួរស្រាវជ្រាវ..... ៦

១.៦. សារៈសំខាន់នៃការស្រាវជ្រាវ ..... ៦

១.៧. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ..... ៧

១.៧.១. វិសាលភាពនៃការស្រាវជ្រាវ..... ៧

១.៧.២. ដែនកំណត់នៃការស្រាវជ្រាវ..... ៧

១.៨. វិធីសាស្ត្រស្រាវជ្រាវ ..... ៧

១.៨.១. វិធីសាស្ត្រប្រមូលទិន្នន័យ..... ៧

ក. ទិន្នន័យចម្បង ....... ៧

ខ. ទិន្នន័យបន្ទាប់បន្សំ ....... ៧

១.៨.២. វិធីសាស្ត្របង្កើតកម្រងសំណួរ ....... ៧

១.៨.២.១. កម្រងសំណួរពហុជ្រើសរើសបង្ហាញពីកម្រិតយល់ដឹង ពីទាបទៅខ្ពស់ ....... ៨

១.៨.២.២. កម្រងសំណួរបើកបង្ហាញពីទស្សនៈរបស់គាត់ ....... ៨

១.៩. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....... ៨

ជំពូកទី២ រំលឹកទ្រឹស្តី ....... ១០

២.១. សេចក្តីទូទៅ ....... ១០

២.២. ពាក្យគន្លឹះ និងទ្រឹស្តី ....... ១១

២.៣. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ....... ១៥

២.៤. លក្ខណៈសម្បត្តិរបស់គ្រូបង្រៀនក្នុងសតវត្សទី២១ ....... ១៨

២.៥. កំណែទម្រង់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនរបស់ក្រសួងអប់រំ ....... ២០

២.៥.១. គោលនយោបាយស្តីពីគ្រូបង្រៀន ....... ២០

២.៥.២. កំណែទម្រង់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ....... ២១

២.៥.៣. កំណែទម្រង់ជាអាទិភាពសម្រាប់ឆ្នាំ២០១៤-២០១៨ ....... ២១

២.៥.៤.កំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៨-២០២៣ ....... ២២

២.៦. វិទ្យាស្ថានជាតិអប់រំ ....... ២៤

២.៧.  កម្មវិធីពន្លឿន ....... ២៦

២.៨. ការលើកទឹកចិត្តគ្រូបង្រៀន ....... ២៧

២.៩. សង្ខេបរំលឹកទ្រឹស្តី ....... ២៨

ជំពូកទី ៣ វិធីសាស្ត្រស្រាវជ្រាវ ....... ៣១

៣.១. ដំណើរការនៃការស្រាវជ្រាវ ....... ៣១

៣.២. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣១

៣.៣. ឧបករណ៍ស្រាវជ្រាវ ........ ៣១

៣.៤. ការជ្រើសរើសភាគសំណាក ........ ៣២

៣.៥. ការវិភាគទិន្នន័យ ........ ៣៤

៣.៦. របៀបនៃការបង្ហាញព័ត៌មាន ........ ៣៥

ជំពូកទី៤ ៖ លទ្ធផល ........ ៣៧

៤.១. មុខងារបច្ចុប្បន្ន និងបទពិសោធន៍ការងារ ........ ៣៧

  ៤.១.១. តួនាទី ........ ៣៧

  ៤.១.២. បទពិសោធន៍ ........ ៣៨

  ៤.១.៣. កម្រិតវប្បធ៌មគ្រូបង្រៀន ........ ៣៩

  ៤.១.៤. ចំនួនអ្នកចូលរួមវគ្គពន្លឿន ........ ៤០

  ៤.១.៥. ចំនួនអ្នកចូលរួមវគ្គពន្លឿនតាមមុខវិជ្ជាឯកទេស ........ ៤១

៤.២. ការយល់ឃើញលើវគ្គបណ្តុះបណ្តាល ........ ៤២

  ៤.២.១. កម្រិតនៃការពេញចិត្ត លើរយៈពេលនៃការបណ្តុះបណ្តាល ........ ៤២

  ៤.២.២. ទស្សនៈយល់ឃើញគ្រូពន្លឿន ចំពោះគ្រូឧទ្ទេស ........ ៤៥

  ៤.២.៣. ទស្សនៈយល់ឃើញរបស់គ្រូពន្លឿន លើសមត្ថភាពរបស់ខ្លួន ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល ........ ៤៨

  ៤.២.៣. ទស្សនៈយល់ឃើញរបស់គ្រូពន្លឿន ទៅលើការសិក្សារបស់សិស្ស ........ ៥០

៤.៣. ទស្សនៈគ្រូដែលមិនបានចូលរួមវគ្គពន្លឿន ........ ៥២

  ៤.៣.១. កម្រិតនៃការពេញចិត្ត នៃរយៈពេលបណ្តុះបណ្តាល ........ ៥២

  ៤.៣.២. ទស្សនៈយល់ឃើញរបស់គ្រូ លើគ្រូពន្លឿន ........ ៥៥

៤.៤. ការប្រៀបធៀបទស្សនៈយល់ឃើញ គ្រូ និងគ្រូពន្លឿន ........ ៥៨

៤.៤.១. ការប្រៀបធៀបគ្រូពន្លឿន ដោយផ្អែកលើភេទ ........................................ ៥៨
៤.៤.២. ការប្រៀបធៀបគ្រូពន្លឿន ដោយផ្អែកលើបទពិសោធន៍ការងារ ........................... ៦២
៤.៤.៣. ការប្រៀបធៀបគ្រូ និងគ្រូពន្លឿន ........................................ ៦៦
៤.៤.៤. ការប្រៀបធៀបគ្រូ និងគ្រូពន្លឿនដោយផ្អែកលើភេទ ........................................ ៦៩
៤.៤.៥. ការប្រៀបធៀបគ្រូ និងគ្រូពន្លឿនដោយផ្អែកលើបទពិសោធន៍ការងារ ........................... ៧២
ជំពូកទី៥ សេចក្តីសន្និដ្ឋាន ការពិភាក្សានិងសំណូមពរ ........................................ ៧៧
៥.១. សេចក្តីសនិដ្ឋាន ........................................ ៧៧
៥.២. ការពិភាក្សាចំពោះលទ្ធផល ........................................ ៧៨
៥.២.១. គោលបំណងទី ១ ........................................ ៧៨
៥.២.២. គោលបំណងទី ២ ........................................ ៧៩
ឯកសារយោង ........................................ ៨៣
ឧបសម្ព័ន្ធទី១ ........................................ ៨៨
ឧបសម្ព័ន្ធទី២ ៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជន និងកីឡា ........................................ ៨៩
ឧបសម្ព័ន្ធទី៣ ៖ កម្រងសំណួរ ........................................ ៩០

# បញ្ជីតារាង


តារាងទី ១.១. ចំនួនប្រជាជនខេត្តស្វាយរៀង........................................................................២

តារាងទី ២.១. តារាងស្ថិតិគ្រូនៅ វិទ្យាស្ថានជាតិអប់រំ............................................................២៥

តារាងទី ២.២. ចំនួនគ្រូពន្លឿនដែលបានទទួលការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំ................២៥

តារាង ៣.១. ចំនួនសំណាកអ្នកចូលរួម..................................................................................៣៣

តារាងទី ៤.១. ៖ បង្ហាញពីតម្លៃមធ្យម គំលាតស្តង់ដា អត្ថន័យ លំដាប់ ទស្សនៈរបស់គ្រូ ទៅលើ គុណភាពសាស្ត្រាចារ្យ ដែលជាគ្រូឧទ្ទេស គ្រូពន្លឿន..................................... ៤៥

តារាងទី ៤.២. ៖ បង្ហាញពីតម្លៃមធ្យម គំលាតស្តង់ដា អត្ថន័យ លំដាប់ ទស្សនៈរបស់គ្រូពន្លឿន ទៅ លើការសិក្សារបស់ពួកគាត់ក្រោយវគ្គបណ្តុះបណ្តាល...................................... ៤៨

តារាងទី ៤.៣. ៖ បង្ហាញពីតម្លៃមធ្យម គំលាតស្តង់ដា អត្ថន័យ លំដាប់ ទស្សនៈយល់ឃើញរបស់គ្រូ ពន្លឿន ទៅលើការសិក្សារបស់សិស្ស.......................................................... ៥០

តារាងទី ៤.៤. ៖ បង្ហាញពីតម្លៃមធ្យម គំលាតស្តង់ដា អត្ថន័យ លំដាប់ ទស្សនៈរបស់គ្រូមិន បាន បណ្តុះបណ្តាលវគ្គពន្លឿន ទៅលើគ្រូពន្លឿន................................................... ៥៥

តារាងទី ៤.៥. ៖ បង្ហាញពីតម្លៃមធ្យម គំលាតស្តង់ដា អត្ថន័យ លំដាប់ ទស្សនៈរបស់គ្រូមិន បាន បណ្តុះបណ្តាលវគ្គពន្លឿន ទៅលើការសិក្សារបស់សិស្ស...................................៥៧

តារាងទី ៤.៦. ៖ បង្ហាញពីការប្រៀបធៀប ទស្សនៈគ្រូពន្លឿន លើស្ថានភាពនៃវគ្គបណ្តុះបណ្តាល គ្រូពន្លឿនដោយផ្អែកលើភេទ ..................................................................... ៥៩

តារាងទី ៤.៧. ៖ បង្ហាញពីការប្រៀបធៀប ទស្សនៈគ្រូពន្លឿន លើស្ថានភាពនៃវគ្គបណ្តុះបណ្តាល គ្រូពន្លឿនដោយផ្អែកលើបទពិសោធន៏ការងារ.................................................៦២

តារាងទី ៤.៨. ៖ បង្ហាញពីការប្រៀបធៀបទស្សនៈរវាងលោកគ្រូពន្លឿន និងគ្រូមិនពន្លឿន ក្រោយ វគ្គបណ្តុះបណ្តាល............................................................................................ ៦៦

តារាងទី ៤.៩. ៖ បង្ហាញពីការប្រៀបធៀប ទស្សនៈរវាងគ្រូពន្លឿន និងគ្រូមិនពន្លឿន លើ

ស្ថានភាពនៃវគ្គបណ្តុះបណ្តាល ដោយផ្អែកលើភេទ ........................................ ៦៩
តារាងទី៤.១០៖ បង្ហាញពីការប្រៀបធៀបទស្សនៈរវាងគ្រូពន្លឿន និងគ្រូមិនពន្លឿន លើស្ថានភាពនៃវគ្គបណ្តុះបណ្តាល ដោយផ្អែកលើបទពិសោធន៍ការងារ...........................៧៣

# បញ្ជីរូបភាព


រូបភាពទី ៤.១. តួនាទីរបស់អ្នកចូលរួមបំពេញកម្រងសំណួរ....................................................៣៧

រូបភាពទី ៤.២.  បទពិសោធន៍បំពេញការងារ.........................................................................៣៨

រូបភាពទី ៤.៣. កម្រិតវប្បធម៌គ្រូបង្រៀន ............................................................................ ៤០

រូបភាពទី ៤.៤. ចំនួនគ្រូបាន និងមិនបានចូលរួមវគ្គពន្លឿន........................................................ ៤១

រូបភាពទី ៤.៥. ចំនួនគ្រូបានចូលរួមវគ្គពន្លឿនតាមមុខវិជ្ជាឯកទេស........................................... ៤២

រូបភាពទី ៤.៦. ចំនួនគ្រូបានចូលរួមវគ្គពន្លឿនតាមមុខវិជ្ជាឯកទេស............................................៤៣

រូបភាពទី ៤.៧. គុណភាពសិក្សារបស់សិស្សវាអាស្រ័យលើកត្តាផ្សេងៗថែមទៀត .......................... ៤៤

រូបភាពទី ៤.៨. រយៈពេលអាចប៉ះពាល់ដល់ការសិក្សារបស់សិស្ស............................................... ៤៥

# មូលន័យសង្ខេប

កម្ពុជាមានព្រំដែនដីគោក ខាងជើងនិងខាងលិច ជាប់ប្រទេសថៃ ៨០០គ.ម ជាប់ប្រទេសឡាវ ៥៤១ គ.ម ភាគខាងឥសាននិងជាប់ប្រទេសវៀតណាម១២២៨គ.មភាគខាងកើតនិងអាគ្នេយ៍ ។ តាមជំរឿនឆ្នាំ ២០១៩ ប្រជាជនកម្ពុជាមាន១៥ ២៨៨ ៤៨៩ នាក់ ក្នុងនោះភេទស្រីមាន ៧ ៨៦៩ ៩១២ នាក់ ។ តាមស្ថិតិគ្រូខេត្តស្វាយរៀងឆ្នាំ ២០១៩ គ្រូវិទ្យាល័យមាន ៤៨៦នាក់ ស្រី៩៦នាក់ គ្រូអនុវិទ្យាល័យមាន ២០៥៥នាក់ ស្រី៥៦៥នាក់ និងគ្រូបឋមមាន ២៣២៦នាក់ ស្រី ៩០២នាក់ ។ ការសិក្សាស្រាវជ្រាវ ស្តីពីទស្សនៈយល់ឃើញរបស់គ្រូពន្លឿន និងលោកគ្រូ អ្នកគ្រូ ទៅលើគ្រូពន្លឿនក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ។ កម្មវិធីពន្លឿន គឺជាកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់គ្រូបង្រៀនដែលពួកគាត់ត្រូវបណ្តុះបណ្តាលក្នុងរយៈពេលខ្លី គឺជាមធ្យម ៦០ក្រេឌីត ហើយអាចផ្លាស់ប្តូរក្របខណ្ឌ ពីគ្រូបង្រៀនកម្រិតមូលដ្ឋានទៅ ជាគ្រូបង្រៀនកម្រិតឧត្តម បង្រៀននៅតាមវិទ្យាល័យនានា។

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង២៖ (១) រកឱ្យឃើញនូវទស្សនៈរបស់គ្រូ និងគ្រូពន្លឿនក្រោយវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ (២) ប្រៀបធៀបទស្សនៈគ្រូ និងគ្រូពន្លឿន ក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ដោយផ្អែកលើភេទ និងបទពិសោធន៍ការងារ។ ការសិក្សាស្រាវជ្រាវធ្វើឡើងតាមបែបបរិមាណវិស័យ ហើយភាគសំណាកក្នុងការសិក្សានេះគឺ គ្រូបង្រៀនចំនួន ១០៤នាក់ ដែលកំពុងបង្រៀន ទាំង៧វិទ្យាល័យ ៧ក្រុង/ស្រុក ក្នុងខេត្តស្វាយរៀង។ ក្នុងសំណាកគ្រូ១០៤នាក់ មានគ្រូពន្លឿនចំនួន ៥៥នាក់ និងគ្រូមិនបានពន្លឿនចំនួន៤៩នាក់ បានចូលរួមបំពេញកម្រងសំណួរ។ ឧបករណ៍ដែល ប្រើប្រាស់សម្រាប់ការស្រាវជ្រាវនេះគឺ កម្រងសំណួរបង្កើតឡើងតាម Google form ដែលរៀបចំឡើងដោយអ្នកស្រាវជ្រាវ។ ទិន្នន័យដែលប្រមូលបានត្រូវបាន វិភាគដោយស្ថិតិ ដូចជាតម្លៃភាគរយ (%) តម្លៃមធ្យម (Mean) គម្លាតស្តង់ដា (S.D.), Independent Sample t-Test និង One-way ANOVA។ លទ្ធផលសំខាន់ៗនៃការសិក្សាស្រាវជ្រាវនេះ អាចសរុបបានដូចខាងក្រោម៖

១- លោកគ្រូអ្នកគ្រូក្នុងខេត្តស្វាយរៀងយល់ឃើញថា សមត្ថភាពរបស់គ្រូពន្លឿន មានកម្រិតមធ្យមដែលអាចមានផលជះលើការសិក្សារបស់សិស្សក៏បានកម្រិតកម្រិតមធ្យមដែរ។ បើរៀបលំដាប់តម្លៃមធ្យម

ពីខ្ពស់មកទាប គ្រូពន្លឿនទទួលបានចំណោះឯកទេសបានលេខ១ និង សិស្សមានមោទនៈភាពលើគ្រូបង្រៀនបានចំណាត់ថ្នាក់លេខ១។

២- លទ្ធផលប្រៀបធៀបទស្សនៈគ្រូបង្រៀនទៅលើ គ្រូពន្លឿនដែលកំពុងបង្រៀននៅ កម្រិតមធ្យមសិក្សាទុតិយភូមិ ឃើញថាគ្រូបង្រៀនដែលមានភេទ និងបទពិសោធន៍ការងារផ្សេងគ្នាមានទស្សនៈយល់ឃើញខុសគ្នា។

ABSTRACT

Cambodia has the border to the north of Thailand and west 800 km to Laos 541Km northeast and adjacent to Vietnam 1228 km east and southeast. According to the 2019 census, the population of Cambodia is 15,288,489, of which 7,869,912 are females. According to the statistics of Svay Rieng province in 2019, there were 486 high school teachers, 96 females, 2055 secondary school teachers, 565 females and 2326 primary teachers, 902 females. study is about the perceptions of accelerated educators and teachers on accelerated teachers after training at National Institute of Education. Accelerated Program is a professional development program for teachers where they have to train for a short period of time, an average of 60 credits, and can change the framework from basic teachers to higher teachers at high schools.

Two purposes of this research are to: (1) find out the views of teachers and accelerators after the training at the National Institute of Education (2) to compare the views of teachers on the accelerators after the training at the National Institute of Education by sex and work experiences. The study was conducted on a quantitative and the sample size of this study was 104 teachers who were teaching in 7 high schools in 7 towns / districts in Svay Rieng province. Out of 104 teachers, 55 accelerated teachers and 49 non-accelerators participated in the questionnaire. The tool used for this research is a questionnaire created via Google form prepared by the researcher. Collected data is analyzed statistically, such as percentage values (%) Mean Value (Mean) Standard Deviation (S.D.) Independent Sample t-Test and One-way, ANOVA. The main results of this study can be summarized as follows:

1. Teachers in Svay Rieng province think that the ability of the accelerator teacher is moderate, which can have an effect on the student's learning as well as moderate level. If we rank questionnaires from higher to lower, accelerated teachers will get the first specialized knowledge. Students are proud of their teacher, ranked No. 1.

2. The results of comparing teachers' views on accelerated teachers who are teaching at upper secondary level show that teachers of different genders and have the same opinions and different work experiences and have different opinion.

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. លក្ខណៈប្រជាសាស្ត្រ និងភូមិសាស្ត្រ

ខេត្តស្វាយរៀងជាខេត្តមួយជាប់ព្រំប្រទល់ ខាងកើតជាប់ប្រទេសវៀតណាមខាងជើងជាប់ខេត្តកំពង់ចាម ខេត្តព្រៃវែង ប្រជាជន៩០%ប្រកបមុខរបកសិកម្ម ១០%ជាអ្នករកទទួលទាន អាជីករ មន្ត្រីរាជការ និងបម្រើសេវាំផ្សេងៗ។ កម្ពុជាមានផ្ទៃដីសរុប ១៨១ ០៣៥ គីឡូម៉ែតការ៉េ ខេត្តមានប្រជាជនសរុបចំនួន៤៨២,៧៨៨នាក់ ស្រី២៥១,២១០នាក់ គ្រួសារមានចំនួន១១៥,២៥៣គ្រួសារ ក្នុងមួយគ្រួសារជាមធ្យមមានសមាជិក០៤។ ខេត្តស្វាយរៀងមាន៦ស្រុក ក្រុងចំនួន២ ឃុំចំនួន៧២ និង៨សង្កាត់។

នៅខេត្តស្វាយរៀងមានវិទ្យាល័យចំនួន ២០ អនុវិទ្យាល័យ ៥៥ បឋមសិក្សាមាន ២៦៣ បុគ្គលិកអប់រំ គ្រូវិទ្យាល័យមាន ៤៨៦នាក់ ស្រី៩៦នាក់ គ្រូអនុវិទ្យាល័យមាន២០៥៥នាក់ ស្រី៥៦៥នាក់ និងគ្រូបឋមមាន ២៣២៦នាក់ ស្រី ៩០២នាក់។

តារាងទី ១.១. ចំនួនប្រជាជនខេត្តស្វាយរៀង

| ខេត្ត ស្រុក | ចំនួនគ្រួសារសរុប | ចំនួនប្រជាជនសរុប តាមភេទ | | | ទំហំគ្រួសារជាមធ្យម |
|---|---|---|---|---|---|
| | | ចំនួនសរុប | ប្រុស | ស្រី | |
| ប្រជាជនខេត្តស្វាយរៀង | | | | | |
| **សរុប** | **១១៥,២៥៣** | **៤៨២,៧៨៨** | **២៣១,៥៧៨** | **២៥១,២១០** | **៤.២** |
| ប្រជុំជន | ៣,៦៣២ | ១៧,០២៩ | ៨,២៥៩ | ៨,៧៧០ | ៤.៦ |
| ជនបទ | ១១១,៦២១ | ៤៦៥,៧៥៩ | ២២៣,៣១៩ | ២៤២,៤៤០ | ៤.២ |
| ចំនួនប្រជាជនតាមស្រុក | | | | | |
| 01 ស្រុក ចន្ទ្រា | ៥,៦២៨ | ២៤,៩០៤ | ១២,២០១ | ១២,៧០៣ | ៤.៤ |
| 02 ស្រុក កំពង់រោទិ៍ | ១៣,៨០៦ | ៥៧,៧៣២ | ២៨,០៥១ | ២៩,៦៨១ | ៤.២ |
| 03 ស្រុក រំដួល | ១១,៦៨៤ | ៤៦,៩៤៤ | ២២,២៨៤ | ២៤,៦៦០ | ៤.០ |

| | | | | | |
|---|---|---|---|---|---|
| 04 ស្រុក រមាសហែក | ២៦,៨៥០ | ១០៩,០៦៨ | ៥២,០៤៩ | ៥៧,០១៩ | ៤.១ |
| 05 ស្រុក ស្វាយជ្រុំ | ៣០,០១៤ | ១២០,៣១៨ | ៥៧,២៦២ | ៦៣,០៥៦ | ៤.០ |
| 06 ក្រុង ស្វាយរៀង | ៨,៩៧១ | ៤០,៥៣៦ | ១៩,៤២៤ | ២១,១១២ | ៤.៤ |
| 07 ស្រុក ស្វាយទាប | ១០,៦៤២ | ៤៦,១៦៣ | ២២,០១៩ | ២៤,១៤៤ | ៤.៣ |
| 08 ក្រុង បាវិត | ៧,៦៥៨ | ៣៧,១២៣ | ១៨,២៨៨ | ១៨,៨៣៥ | ៤.៨ |

ប្រភព៖ ជំរឿងប្រជាជនឆ្នាំ២០០៨ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ

## ១.២. លំនាំបញ្ហា

គ្រូបង្រៀនគឺជាសមាសធាតុដ៏សំខាន់នៃការអប់រំក្នុងការសម្រេចគោលដៅអប់រំ។ គ្រូក៏ជាមនុស្សសំខាន់បំផុតក្នុងការបង្រៀនដែលរៀបចំបរិយាកាស និងបទពិសោធន៍រៀនសូត្រ។ ក្នុងការបង្រៀនគ្រូបង្រៀនប្រើ ចំណេះដឹង ជំនាញ អាកប្បកិរិយា ការអនុវត្ត និងសមិទ្ធិផលនៃការសិក្សារបស់សិស្ស គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើការត្រៀមខ្លួនរបស់គ្រូក្នុងការបង្កើតឱ្យមានសកម្មភាព (Namunga and Otunga, 2012) ។ គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការបង្រៀន និងរៀនដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស និងមានឥទ្ធិពលទៅលើការសិក្សារៀនសូត្ររបស់សិស្ស (Darling-Hammond, Wei, និង Johnson ឆ្នាំ ២០១២) ។ ការសិក្សាបង្ហាញថា គ្រូបង្រៀនមានឥទ្ធិពល ទៅលើលទ្ធផលសិក្សារបស់សិស្ស។ ហើយការសិក្សានេះទៀតសោតបង្ហាញឱ្យដឹងថា គ្រូបង្រៀនអាចកំណត់ភាពខុសគ្នានៃការរៀនសូត្ររបស់សិស្ស ហើយពួកគេក៏អាចធ្វើឱ្យមានភាពខុសប្លែកគ្នាកាន់តែធំទៅនឹង ភាពជោគជ័យនៃការអប់រំរបស់សិស្ស (Darling-Hammond, 2006) ។ ឥទ្ធិពលរបស់គ្រូល្អ ឬអាក្រក់មិនត្រឹមតែជះឥទ្ធិពលដល់ការរៀនសូត្ររបស់សិស្សតែមួយឆ្នាំប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានឥទ្ធិពលនៅក្នុងឆ្នាំបន្តបន្ទាប់ផងដែរ។

នៅក្នុងរំលឹកទ្រឹស្តីក្នុងកិច្ចការស្រាវជ្រាវជាច្រើនបានបង្ហាញថា គ្រូត្រូវមានសមត្ថភាពខ្លាំង ការបង្រៀនល្អ ទាមទាឱ្យមានការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ ក្នុងការចូលរួមចំណេះដឹង ដើម្បីដោះស្រាយបញ្ហានាពេល បច្ចុប្បន្ន និងការអនុវត្តភារកិច្ចប្រកបដោយក្រមសីលធម៌ និងបង្ហាញការប្តេជ្ញាចិត្តឬទំនួលខុសត្រូវក្នុងការអនុវត្តការបង្រៀននៅសាលា។ គ្រូក៏តម្រូវឱ្យចូលរួមក្នុងឱកាសសិក្សាក្នុងការអភិវឌ្ឍវិជ្ជាជីវៈដូច

ជាសិក្ខាសាលាណែនាំនិងបណ្តុះបណ្តាលដើម្បីគាំទ្រតួនាទីរបស់ពួកគាត់ (Tanang and Abu, 2014) ។ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនគឺជាអាទិភាពនៃប្រព័ន្ធអប់រំ ហើយគ្រូខ្លួនឯង ត្រូវការធ្វើបច្ចុប្បន្នភាពជំនាញនិងចំណេះដឹង។ ការសិក្សាបានបង្ហាញថាកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈការអភិវឌ្ឍចំណេះដឹងខាងគរុកោសល្យ បង្កើនទំនុកចិត្តលើការបង្រៀន ហើយក៏បង្កើតឥរិយាបថវិជ្ជមានលើការបង្រៀន និងការសិក្សារបស់សិស្សផងដែរ (Radford, ១៩៩៨; Stan et al. , ១៩៩៩) ។ ការជួយគ្រូឱ្យធ្វើបច្ចុប្បន្នភាពចំណេះដឹងនិងជំនាញរបស់ពួកគេ គឺដើម្បីដោះស្រាយជាមួយនឹងការផ្លាស់ប្តូរក៏ដូចជាការគ្រប់គ្រងធនធានមនុស្ស គឺចាំបាច់ ហើយការអភិវឌ្ឍវិជ្ជាជីវៈជួយគ្រូបង្រៀនឱ្យទទួលបានសមិទ្ធិផលល្អប្រសើរ (Tanang & Abu, 2014) ។ ស្នូលនៃការអភិវឌ្ឍវិជ្ជាជីវៈគ្រូគ្រូបង្រៀន គឺនិយាយការសិក្សារបស់គ្រូបង្រៀន និងរៀនដើម្បីទទួលយកចំណេះដឹង និងអាចផ្ទេរចំណេះដឹងរបស់ពួកគេទៅឱ្យសិស្ស និងជាប្រយោជន៍ដល់ការលូតលាស់របស់សិស្សរបស់ពួកគាត់ (Avalos, 2011)។

នៅក្នុងកម្មវិធីពន្លឿននេះអនុញ្ញាតឱ្យគ្រូមាន ឱកាសច្រើនក្នុងការរៀននូវអ្វីដែលគ្រូគួរធ្វើនិងចាំបាច់ត្រូវដឹងដើម្បីឱ្យមានប្រសិទ្ធិភាពហើយកម្មវិធីនេះ ត្រូវបានគេជឿជាក់ថានឹងធ្វើអោយប្រសើរឡើងនូវគុណភាពរបស់គ្រូ (Republika, 2014)។ ដើម្បីឱ្យមានការអភិវឌ្ឍជឿនលឿនជានិរន្តរ៍ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ក្រសួងអប់រំយុវជន និងកីឡាចាំបាច់បំផុតនោះត្រូវយកចិត្តទុកដាក់ ទៅលើនាយកសាលា គ្រូបង្រៀន និងកម្មវិធីសិក្សា។ ក្នុងចំណោមធាតុសំខាន់ទាំងបី គ្រូបង្រៀនជាផ្នែកមួយដ៏សំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្សពីព្រោះគ្រូបង្រៀនជាអ្នកប្រឡូកជាមួយសិស្សានុសិស្ស និងជាអ្នកអនុវត្តផ្ទាល់លើកម្មវិធីសិក្សាផងដែរ។ ដើម្បីឱ្យការអនុវត្តបានបំពេញភារកិច្ចការងាររបស់ខ្លួនបានកាន់តែប្រសើរគ្រូបង្រៀនចាំបាច់ត្រូវតែគិតគូរទៅលើការអភិវឌ្ឍវិជ្ជាជីវគ្រូបង្រៀន ។ ក្នុងរយៈពេលកំណែទម្រង់ជាងពីរអាណត្តិ ជាពិសេសគឺផ្តោតលើគ្រូ គឺពង្រឹងគុណវុឌ្ឍិគ្រូបង្រៀន បង្កើនគ្រូបង្រៀនស្តង់ដាអាស៊ាន តាមរយៈកម្មវិធីពន្លឿនគ្រូកម្រិតមូលដ្ឋាន ឆ្ពោះទៅរកគ្រូបរិញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ។ បើតាមលទ្ធផលនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំការបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋាន ដែលកំពុងបង្រៀននៅវិទ្យាល័យ តាមប្រព័ន្ធពន្លឿនដើម្បីឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្តម ២៦៨៦នាក់ ស្រី៩៣៤នាក់ ស្មើ

នឹង (៣៤.៧ ភាគរយ)។ ទោះបីជាមានគ្រូបង្រៀនកម្រិតមូលដ្ឋានជាច្រើនបានបញ្ចប់វគ្គបណ្តុះបណ្តាលនេះ គុណភាពសិក្សា របស់សិស្សហាក់បីដូចមិនមាន ការប្រែប្រួលដែលគួរឱ្យកត់ សម្គាល់នៅឡើយទេ។

ការសិក្សា នេះមានគោលបំណងស្វែងយល់ពីការយល់ឃើញរបស់គ្រូ ដែលបានបញ្ចប់ការសិក្សាក្នុងកម្មវិធីពន្លឿនឆ្ពោះទៅរកបរិញ្ញាបត្រ ដែលពួកគេបានចូលរួមដើម្បីអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគេ និងការយល់ឃើញរបស់គ្រូដែលមិនបានចូលរួមក្នុងកម្មវិធីនេះ អាចផ្តល់នូវបរិបទឆ្លុះបញ្ចាំងសម្រាប់ការពិភាក្សាបន្ថែមលើការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន។ ការពិនិត្យមើល និងការយល់ឃើញរបស់គ្រូចំពោះកម្មវិធីពន្លឿនឆ្ពោះទៅរកបរិញ្ញាបត្រ សំខាន់ណាស់ ព្រោះកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន អាចឱ្យគ្រូយល់ដឹងអំពីប្រសិទ្ធិភាពនៃវិធីសាស្ត្រដែលពួកគាត់បានប្រើនៅក្នុងវគ្គសិក្សារបស់ពួកគេ( Tarman,ឆ្នាំ ២០១២ ) ។

## ១.៣. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យអប់រំត្រូវបានគេទទួលស្គាល់ថា ជាថ្នូរបណ្តុះបណ្តាលវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា ឱ្យក្លាយជាមនុស្សពេញលេញ ក្នុងសង្គមដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍសេដ្ឋកិច្ចជាតិសន្តិភាពសេចក្តីថ្លៃថ្នូរ មានវប្បធម៌សន្ទនាចេះ ស្រលាញ់និងជួយថែរក្សាវប្បធម៌ជាតិឱ្យបានគង់វង្សនិងកាត់បន្ថយជីវភាពក្រីក្រនៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋហើយតួនាទីក្នុងវិស័យនេះជាបន្ទុកគ្រប់គ្រងដ៏ពិសិដ្ឋរបស់ក្រសួងអប់រំយុវជន និងកីឡា។ គ្រូបង្រៀនគឺជាបុគ្គលមិនអាចខ្វះបាន ក្នុងការអភិវឌ្ឍប្រទេសជាតិ ពីព្រោះគាត់ជាអ្នកបណ្តុះបណ្តាលអ្នកសិក្សាទាំងអស់ឱ្យក្លាយជាបញ្ញវន្ត ប្រកបដោយចំណេះដឹងខ្ពស់សម្បូរធនធានមនុស្សពេញលេញ និងជាពលរដ្ឋថ្លៃថ្នូរដើម្បីរួមគ្នាកសាងប្រទេសជាតិឱ្យរីកចម្រើនគ្រប់ហេដ្ឋារចនាសម្ព័ន្ធ។ គ្រូបង្រៀនគឺជាឆ្អឹងខ្នងនៃគុណភាពអប់រំ និងជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍធនធានមនុស្ស។ ការអប់រំប្រកបដោយគុណភាពត្រូវចាប់ផ្តើមពីគ្រូបង្រៀនល្អ។ ដើម្បីជាការទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់គ្រូបង្រៀនក្នុងការកែលម្អគុណភាពអប់រំ ការឱ្យតម្លៃគ្រូបង្រៀនគឺជាការលើកកម្ពស់ស្ថានភាពរបស់ពួកគាត់។ កំណែទម្រង់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន តាមរយៈកម្មវិធីពន្លឿនគ្រូ

កម្រិតមូលដ្ឋាន ឆ្ពោះទៅរកបរិញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ របស់ក្រសួងអប់រំ ក្នុងន័យដើម្បីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន រៀបចំគន្លងអាជីពគ្រូបង្រៀន ក៏ដូចជាគោលនយោបាយគ្រូបង្រៀន (TPAP) ដើម្បីធានាបាននូវលទ្ធផលសិក្សារបស់សិស្សដែលអាចទទួលយកបាន តាមស្តង់ដាអាស៊ាន និងសកលលោក។ ដូចនេះដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្រសួងអប់រំយុវជននិងកីឡា និងក្រសួងពាក់ព័ន្ធក្នុងវិស័យអប់រំ យុវជន និង កីឡា អ្នកស្រាវជ្រាវ បានសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវ អំពី កំណែទម្រង់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ដោយផ្តោតលើកម្មវិធីពន្លឿនគ្រូកម្រិតមូលដ្ឋាន ឆ្ពោះទៅរកបរិញ្ញាបត្រ។

## ១.៤. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវនេះមានគោលបំណងពីរៈ

ក. រកឱ្យឃើញនូវទស្សនៈរបស់គ្រូនិងគ្រូពន្លឿនក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ។

ខ. រកឱ្យឃើញពីការប្រៀបធៀបទស្សនៈរបស់គ្រូ និងគ្រូពន្លឿនដោយផ្អែកលើ ភេទ និងបទពិសោធន៍ការងារ។

## ១.៥. សំណួរស្រាវជ្រាវ

សំណួរស្រាវជ្រាវនៃប្រធានបទខាងលើនេះគឺៈ

ក. តើទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំមានលក្ខណៈដូចម្តេចខ្លះ ?

ខ. តើការប្រៀបធៀបទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនដោយផ្អែកលើ ភេទ និងបទពិសោធន៍ការងារមានលក្ខណៈដូចម្តេចខ្លះ ?

## ១.៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ណាស់ ក្នុងការចូលរួមចំណែក ស្វែងយល់ពីប្រសិទ្ធិផលនៃកំណែទម្រង់វិស័យអប់រំក្នុងការលើកកម្ពស់ គុណវុឌ្ឍិគ្រូបង្រៀន ទៅលើតួនាទី និងទំនួលខុសត្រូវរបស់គ្រូបង្រៀន តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគាត់ដើម្បីធានាបាននូវគុណភាពសិក្សា

របស់សិស្ស។ មិនត្រឹមតែប៉ុណ្ណោះ វាបានជួយដល់ក្រសួងអប់រំ យុវជន និងកីឡា មើលឃើញពីស្ថានភាពនានារបស់គ្រូបង្រៀននៅតាមអង្គភាពនីមួយៗ ងាយស្រួលក្នុងការដោះស្រាយពីស្ថានភាពទាំងនោះ បញ្ជាបឱ្យដល់គ្រូបានដឹងហើយអនុវត្តន៍បាន គ្រូនឹងមានមុខមាត់ និងសេចក្តីថ្លៃថ្នូរក្នុងសង្គម។ ក្រោយពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវមានសេចក្តីយ៉ាងមុតមាំថា នឹងទទួលបានចំណេះដឹងថ្មីៗ និងបទពិសោធន៍នានាហើយចែករំលែក បទពិសោធន៍ដែលបានរកឃើញដល់អ្នកសិក្សាក្រោយៗ និងទុកជាឯកសារជំនួយស្មារតី ចំពោះការសិក្សាស្រាវជ្រាវផ្សេងៗទៀត។

## ១.៧. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

**១.៧.១. វិសាលភាពនៃការស្រាវជ្រាវ ៖** ការសិក្សាស្រាវជ្រាវនេះធ្វើនៅវិទ្យាល័យចំនួន ៧ ដោយជ្រើសរើសមួយស្រុក មួយវិទ្យាល័យ។

**១.៧.២. ដែនកំណត់នៃការស្រាវជ្រាវ ៖** គណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ និងគ្រូពន្លឿនទាំង ៣ជំនាន់។

## ១.៨. វិធីសាស្ត្រស្រាវជ្រាវ

### ១.៨.១. វិធីសាស្ត្រប្រមូលទិន្នន័យ៖

### ក- ទិន្នន័យចម្បង

ការសិក្សាស្រាវជ្រាវនេះបានធ្វើការសិក្សាលើវិទ្យាល័យចំនួន៧ រួមមាន៖ វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនចន្ទ្រា វិទ្យាល័យកំពង់សំរោង វិទ្យាល័យសម្តេចជាស៊ីមអំពិល វិទ្យាល័យហ៊ុនសែនសាមគ្គីដូនស វិទ្យាល័យហ៊ុនសែនចេក វិទ្យាល័យហ៊ុនសែនស្វាយរំពារ វិទ្យាល័យបារិត ។

### ខ- ទិន្នន័យបន្ទាប់បន្សំ

អ្នកសិក្សាបានស្វែងរកឯកសារមានស្រាប់ដែលពាក់ព័ន្ធជាមួយ នឹងវិស័យអប់រំយុវជន និងកីឡាលើការអនុវត្តកាតព្វកិច្ចរបស់គ្រូបង្រៀនពាក់ព័ន្ធនានា ដែលជាស្នាដៃរបស់និស្សិតជំនាន់មុនៗ។ ការវិភាគ

ទិន្នន័យ បញ្ចូលតាមកម្មវិធី SPSS ទាញជាមធ្យមភាគដែលបានអនុវត្តបាន និងមិនបានអនុវត្តបាន និង កម្មវិធី Microsoft Excel ដើម្បីទាញជាក្រាបសសរហើយបញ្ជាក់ពី គណៈគ្រប់គ្រង និងលោកគ្រូ អ្នកគ្រូ។

### ១.៨.២. វិធីសាស្ត្របង្កើតកម្រងសំណួរ

**១.៨.២.១. កម្រងសំណួរពហុជ្រើសរើសបង្ហាញពីកម្រិតយល់ដឹង ពីទាបទៅខ្ពស់**

**១.៨.២.២. កម្រងសំណួរបើកបង្ហាញពីទស្សនៈរបស់គាត់**

## ១.៩. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជា ៥ជំពូកដូចខាងក្រោម៖

ជំពូកទី១ **សេចក្ដីផ្ដើម** ៖ លំនាំបញ្ហា ចំណោទបញ្ហា នៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជំពូកទី២ **រំលឹកទ្រឹស្ដី** ៖ លើកឡើងពីការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន និងទ្រឹស្ដីមួយចំនួន

ជំពូកទី៣ **វិធីសាស្ត្រស្រាវជ្រាវ** ៖ បង្ហាញពីការប្រមូលសំណាក ប្រមូលព័ត៌មាន និងវិភាគទិន្នន័យ

ជំពូកទី៤ **លទ្ធផលនៃការស្រាវជ្រាវ៖** អ្នកស្រាវជ្រាវបានបង្ហាញពីលទ្ធផលដែលបានពីការស្រាវជ្រាវ

ជំពូកទី៥ **សេចក្ដីសន្និដ្ឋាន និងសំណូមពរ ៖** អ្នកសិក្សាស្រាវជ្រាវធ្វើការសង្ខេបអំពីការសិក្សាស្រាវជ្រាវ រួចទាញជាសេចក្ដីសន្និដ្ឋាន លើចំណុចដែលបានវិភាគ និងផ្ដល់យោបល់ ឬសំណូមពរលើចំណុចដែលត្រូវកែលម្អ។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី ២
# រំលឹកទ្រឹស្តី

## ២.១. សេចក្តីផ្តើម

ការអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាង និងអភិវឌ្ឍធនធានមនុស្សមានគុណភាព សមត្ថភាព និងគុណតម្លៃ ដែលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឱ្យមានការរីកចម្រើន នៃប្រទេសនីមួយៗ ដោយផ្អែកលើមូលដ្ឋានចំណេះដឹង និងជំនាញ។ មានអ្នកស្រាវជ្រាវជាច្រើនបានធ្វើការសិក្សាទៅលើប្រធានបទទាក់ទងសកម្មភាពនៃការអប់រំខុសៗគ្នា ដោយឡែកនៅក្នុងបរិបទកំណែទម្រង់ស៊ីជម្រៅរបស់ក្រសួងអប់រំយុវជន និងកីឡា ឆ្នាំ២០១៩-២០២៣ និងចក្ខុវិស័យឆ្នាំ២០៣០ ធ្វើឱ្យអ្នកស្រាវជ្រាវមានចំណាប់អារម្មណ៍ការសិក្សាស្រាវជ្រាវលើប្រធានបទ ៖ ទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយការ បណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ។

ការសិក្សាស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ណាស់ ក្នុងការចូលរួមចំណែក ស្វែងយល់ពីប្រសិទ្ធិផលនៃកំណែទម្រង់វិស័យអប់រំក្នុងការលើកកម្ពស់ គុណវុឌ្ឍិគ្រូបង្រៀន ទៅលើតួនាទី និងទំនួលខុសត្រូវរបស់គ្រូបង្រៀន តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគាត់ដើម្បីធានាបាននូវគុណភាពសិក្សារបស់សិស្ស។ ការសិក្សានេះបានជួយដល់ក្រសួងអប់រំ យុវជន និងកីឡា មើលឃើញពីស្ថានភាពនានារបស់គ្រូបង្រៀននៅតាមវិទ្យាល័យនីមួយៗ ហើយងាយស្រួលក្នុងការដោះស្រាយពីស្ថានភាពទាំងនោះ ឱ្យទាន់ពេលវេលា បញ្ជ្រាបឱ្យដល់គ្រូបង្រៀន និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាដោយបានចាត់ទុកការអភិវឌ្ឍធនធានមនុស្ស ជាអទិភាពទី១។ ក្រសួងអប់រំ យុវជន និងកីឡាសម្រេចឱ្យបាននូវមុំទី១ ស្តីពី " ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" ដោយផ្តោតលើ ១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រីកអធិការកិច្ច

គ្រប់ជ្រុងជ្រោយលើការងារគ្រប់គ្រងសាលារៀន ៤) ការជំរុញការងារបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ៥) ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ ៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង ៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីការអប់រំឆ្នាំ ២០៣០ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩ - ២០២៣ ដែលមានគោលនយោបាយពីរគឺ ១) ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង ២) ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ដើម្បីសិក្សាឱ្យបានស៊ីសម្រៅលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវមានគោលបំណងសិក្សាអំពីទស្សនៈ ទ្រឹស្តី និងគោលនយោបាយកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ធ្វើជាទឡ្ហីករណ៍ដើម្បីធ្វើការស្រាវជ្រាវលើប្រធានបទ៖ ទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ដោយផ្អែកលើទ្រឹស្តី គោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

## ២.២. ពាក្យគន្លឹះ និងទ្រឹស្តី

**វិជ្ជាជីវៈ** = **វិជ្ជា** + **អាជីវៈ** ពាក្យ**វិជ្ជា** បន្ទាត់ទី១៤ ទំព័រទី៧៣២ មានន័យថាសេចក្តីដឹងច្បាស់ ការចេះដឹង ចំណេះ វេទមន្ត មន្តអាគមន៍។ រីឯពាក្យ**អាជីវៈ** មានន័យថា ជីវិត ការចិញ្ចឹមជីវិត។ វិជ្ជាជីវៈមានន័យថា គឺជាមុខរបរសម្រាប់ចិញ្ចឹមជីវិត (វចនានុក្រមខ្មែរការផ្សាយរបស់ពុទ្ធសាសបណ្ឌិតបោះពុម្ពឆ្នាំ ១៩៦៨ បន្ទាត់ទី២ ទំព័រ ៧៣៣)។ យោងទៅតាម Sanusi (1991), Satori (2007), និង Saud (2010) វិជ្ជាជីវៈគឺជាមុខតំណែងឬការងារដែលត្រូវជំនាញ របស់ខ្លួន។ ពួកគាត់ត្រូវតែមានចំណេះដឹងនិងជំនាញវិជ្ជាជីវៈដែលទទួលបានពីការអប់រំជាក់លាក់ទាក់ទងនឹងវិជ្ជាជីវៈ។ Mohanty (២០០៣ ទំព័រ ២២៥)និយាយអំពីលក្ខណៈនិងលក្ខណៈវិជ្ជាជីវៈមានដូចខាងក្រោម ៖

- វិជ្ជាជីវៈទាមទារឱ្យ មានចំណេះដឹង និងជំនាញឯកទេស ដែលត្រូវការការបណ្តុះបណ្តាល

ជាក់ស្តែង។

- វិជ្ជាជីវៈផ្តល់នូវសេវាសង្គមចាំបាច់សម្រាប់សង្គមទាំងមូល។

- វិជ្ជាជីវៈមួយ ត្រូវការការបណ្តុះបណ្តាលដំបូង (pre-service) ឬបណ្តុះបណ្តាលបន្ត (in-service)

- វិជ្ជាជីវៈទាមទារអោយមានសេរីភាព និងស្វ័យភាពទូលំទូលាយ។

- វិជ្ជាជីវៈជាអាជីពមួយជីវិតមិនមែនការងារក្រៅម៉ោងទេ។

- វិជ្ជាជីវៈវិវត្តទៅជាក្រមសីលធម៌ផ្ទាល់ខ្លួនដែលត្រូវអនុវត្តតាមអង្គភាពរបស់ខ្លួន។

- វិជ្ជាជីវៈត្រូវបានទទួលស្គាល់ដោយរដ្ឋនិងសង្គម។

បន្ថែមលើយោបល់ខាងលើ Darling-Hammond, Wei, and Johnson (២០១២) ពន្យល់ថាជាទូទៅ វិជ្ជាជីវៈកំណត់ស្តង់ដាតាមវិធីបីយ៉ាង។ ទីមួយគឺតាមរយៈការទទួលស្គាល់ជាលក្ខណៈវិជ្ជាជីវៈនៃកម្មវិធីរៀបចំ។ វិជ្ជាជីវៈតម្រូវឱ្យបញ្ចប់ការសិក្សាពីស្ថាប័នបណ្តុះបណ្តាល ដែលមានការទទួលស្គាល់អាជ្ញាប័ណ្ណរដ្ឋតាមរយៈការសាកល្បងចំណេះដឹង និងជំនាញរបស់ពួកគេ។ ទីពីរគឺតាមរយៈការផ្តល់អាជ្ញាប័ណ្ណរបស់រដ្ឋ ដែលផ្តល់ការអនុញ្ញាតឱ្យអនុវត្ត ដើម្បីធានាថាបេក្ខជនត្រូវការចំណេះដឹងដែលពួកគាត់ត្រូវការដើម្បីអនុវត្តការប្រឡងផ្តល់អាជ្ញាប័ណ្ណត្រូវបានរៀបចំឡើង។ ចំណុចទីបី គឺត្រូវមានវិញ្ញាបនប័ត្រ។ វិជ្ជាជីវៈតម្រូវឱ្យមានវិញ្ញាបនប័ត្រជាការទទួលស្គាល់វិជ្ជាជីវៈ។ ពាក្យ "វិជ្ជាជីវៈ" ជាទូទៅចង្អុលបង្ហាញនូវចំណុចពីរយ៉ាងគឺមនុស្សម្នាក់ដែលមានវិជ្ជាជីវៈនិងមុខមាត់របស់មនុស្សម្នាក់ក្នុងការប្រកបអាជីពរបស់ពួកគាត់ (Sanusi, 1991, Satori, 2 007; Saud, 2010) ។ ដើម្បីក្លាយជាអ្នកជំនាញគឺ ទទួលបាននូវជំនាញមួយ តាមរយៈការបណ្តុះបណ្តាលជំនាញ ដែលអាចផ្តល់ជូន ដោយស្ថាប័ន (Hartley and Whitehead, 2006, ទំ.១៧៦) ។ គ្រូម្នាក់ដែលមានវិជ្ជាជីវៈប្រសិនបើគាត់ ជាអ្នកជំនាញលើមុខជំនាញរបស់ពួកគាត់ ហើយមានសមត្ថភាពនិងជំនាញគ្រប់គ្រាន់ដើម្បីក្លាយជាគ្រូបង្រៀន។ អ្វីដែលសំខាន់បំផុតនោះ គឺគាត់ត្រូវតែពូកែជំនាញវិធីសាស្ត្របង្រៀន ព្រោះជំនាញនេះ គឺជាចរិតលក្ខណៈដែលសម្គាល់អាជីពគ្រូ (Budinings ih, ២០០៥) ។ វិជ្ជាជីវៈគឺនិយាយពីគុណភាពការងាររបស់គ្រូនិងបង្ហាញពីទិដ្ឋភាពផ្សេ

ងៗគ្នានៃការបង្រៀន។ វាមិនត្រឹមតែនិយាយពីភាពប៉ិនប្រសប់នៃសមត្ថភាពគ្រប់គ្រងចំណេះដឹងនិងយុទ្ធសាស្ត្រឬការអនុវត្តរបស់វាប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានឥរិយាបថផងដែរ (Tanang & Abu, 2014)។ យោងទៅតាម Helsby (ឆ្នាំ ១៩៩៥) គំនិតនៃវិជ្ជាជីវៈត្រូវបានបង្កើតឡើងនៅក្នុងសង្គមនិងមានភាពខុសគ្នាខាងភូមិសាស្ត្រនិងវប្បធម៌នៅ ក្នុងការបកស្រាយ ដែលអាចផ្លាស់ប្តូរតាមពេលវេលា។ វិជ្ជាជីវៈណែនាំការងាររបស់អ្នកជំនាញនិងទទួលឥទ្ធិពលខ្ពស់ពីការអភិវឌ្ឍន៍ និងគោលនយោបាយ។

**គ្រូបង្រៀន** = **គ្រូ** + **បង្រៀន** ពាក្យគ្រូ = គរុ បន្ទាត់ទី៩ទំព័រទី៩៨មានន័យថា គម្រូ ធ្ងន់។ រីឯពាក្យ បង្រៀន បន្ទាត់ទី២៧ទំព័រ៣៣១មានន័យថា ញុំាងឱ្យអ្នកដ៏ទៃរៀនប្រៀនឱ្យចេះ ឱ្យចំណេះដោយការបង្ហាត់បង្ហាញឱ្យចេះ។ គ្រូបង្រៀនមានន័យថា គឺជាអ្នកមានចិត្តធ្ងន់គួរឱ្យគោរព និងជាអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗ ដល់សិស្ស ឬជាឪពុកទី២ (វចនានុក្រមខ្មែរ ការផ្សាយរបស់ ព្រះពុទ្ធសាសនាបណ្ឌិតបោះពុម្ព ឆ្នាំ១៩៦៨ បន្ទាត់ទី២៧ ទំព័រ៣៣១)។

**វិជ្ជាជីវៈគ្រូបង្រៀន** គឺជាអាជីពមួយ ដែលអាចអនុវត្តចំពោះការងារ ដែលធ្វើទៅតាម លក្ខណៈផ្ទាល់ខ្លួនក្នុងអង្គការ និងស្ថាននយោបាយទូលំទូលាយ (Day, 1999; Helsby, 1995) ។ដើម្បីឱ្យមានជំនាញវិជ្ជាជីវៈគ្រូបង្រៀន ត្រូវប្តេជ្ញាចិត្តចំពោះសិស្ស និងការរៀនសូត្ររបស់ពួកគាត់ ដែលមានភាពស៊ីជម្រៅលើមុខវិជ្ជា និងរបៀបបង្រៀនពួកគាត់ទទួលខុសត្រូវ តាមដានលទ្ធផលសិក្សា របស់សិស្ស តាមរយៈមធ្យោបាយវាយតម្លៃផ្សេងៗមានសមត្ថភាពគិតជាប្រព័ន្ធ។ និងគួរតែជាផ្នែកមួយនៃសហគមន៍សិក្សានៅក្នុងវិជ្ជាជីវៈ (Supriadi, 1998)។

**ការអភិវឌ្ឍវិជ្ជាជីវគ្រូបង្រៀន** គឺជាការរៀនសូត្រពីបទពិសោធន៍ ការកែលម្អសមត្ថភាពរបស់ខ្លួននិងធានាថាចំណេះដឹងជំនាញនិងការយល់ដឹងរបស់ពួកគាត់ក៏មានភាពទាន់សម័យ។ ការផ្លាស់ប្តូរគរុកោសល្យរបស់គ្រូបង្រៀន អាចធ្វើទៅរួចអាស្រ័យលើ មានការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន ដែលអាចឱ្យពួកគាត់ឆ្លុះបញ្ចាំងពីទង្វើរបស់ខ្លួនឯងផ្ទាល់ និងកែលម្អវិជ្ជាជីវៈបន្ថែមទៀត តាមរយៈធ្វើការជាមួយសហសវិកនៅអង្គភាពជាមួយគ្នា(Sari ២០១២) ។ វិជ្ជាជីវៈទាមទារឱ្យមានចំណេះដឹងជំនាញ និងវិជ្ជាជីវៈហើយគោលគំនិតសំខាន់សម្រាប់វិជ្ជាជីវៈនេះ គឺគោលនយោបាយនិងយុទ្ធសាស្ត្រជោគជ័យនៃការ

អភិវឌ្ឍវិជ្ជាជីវៈ (Al-Hinai ២០០៧) ។ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន គឺជាមធ្យោបាយសម្រាប់គ្រូដើម្បីអភិវឌ្ឍចំណេះដឹងនិងជំនាញក្នុងការបង្រៀនសិស្ស។ ការអភិវឌ្ឍវិជ្ជាជីវៈគឺសំដៅទៅលើដំណើរការមួយដែលគ្រូបង្រៀន ពិនិត្យមើលឡើងវិញនិងបន្តការប្តេជ្ញាចិត្តរបស់ពួកគេក្នុងនាមជាភ្នាក់ងារផ្លាស់ប្តូរទៅនឹងគោលបំណងសីលធម៌នៃការបង្រៀនក៏ដូចជាការទទួល និងអភិវឌ្ឍចំណេះដឹងជំនាញផែនការនិងការអនុវត្តជាមួយកុមារ យុវជន និងសហសេវិក តាមរយៈដំណាក់កាលនីមួយៗ នៃការរៀនសូត្ររបស់ពួកគាត់ជាមួយគំនិតនៃការរៀនសូត្រការចូលរួមនិងការអនុវត្តល្អប្រសើរជាងមុន (Day ១៩៩, Bredeson ២០០២) ។ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនមានគោលបំណង លើកកម្ពស់ចំណេះដឹងនិងជំនាញរបស់គ្រូដោយការតំរង់ទិសការបណ្តុះបណ្តាលនិងការគាំទ្រដែលរួមចំណែកក្នុងការកែលំអ។ គុណភាពនៃដំណើរការនៃការរៀននិងបង្រៀន ដោយផ្តោតលើសមត្ថភាពស្នូលរបស់គ្រូដូចជាការលើកកម្ពស់ការបង្រៀនចំណេះដឹងរបស់សិស្សការគ្រប់គ្រងការអនុវត្តវិធីសាស្ត្របង្រៀន និងគរុកោសល្យ(Lessing & De Witt ២០០៧, Tanang et.al ២០១៤) ។ អ្នកសិក្សាស្រាវជ្រាវភាគច្រើនលើការអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀនសំដៅទៅដល់គន្លឹះមួយនៃការកែទម្រង់ក្នុងការបង្រៀន និងការរៀន (Borko, ២០០៤ ; Desimone, ២០០៩; Guskey, ២០០២; Opfer & Pedder, ២០១១) ។ Koster, Dengerink, Korthagen និង Lunenberg (២០០៨) កំណត់ថាការអភិវឌ្ឍវិជ្ជាជីវៈអាច តាមពីរវិធី៖ (១) ដំណើរការដែលក្រុមគ្រូបង្រៀនស្វែយល់ដើម្បី ទទួលបានលក្ខណៈបន្ថែមទៀតដែលត្រូវបានកំណត់ថាជាគ្រូគំរូទាក់ទងនឹងវិជ្ជាជីវៈរបស់ពួកគាត់និង ( ២) ការកែលំអគុណភាពការបង្រៀនដែលផ្តល់ដោយគ្រូបង្រៀនម្នាក់ៗ (ទំព័រ ៥៧០) ។ ការបង្រៀននេះមានប្រសិទ្ធភាពលុះត្រាតែមានការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូទាំងមូល និង ការស្រាវជ្រាវភាគច្រើនលើការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូដោយផ្តោតលើវិធីដែលគ្រូម្នាក់ៗរៀននិងផ្លាស់ប្តូរវិធីសាស្ត្របង្រៀន។ Maskit (២០១១) បានកំណត់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ជាដំណើរការប្រកបដោយ ភាពស្វាហាប់ពេញមួយជីវិតដែលកើតឡើងក្នុងអាជីពរបស់ពួកគេ ថ្នាក់រៀន សាលារៀន និងបរិយាកាសការងាររបស់អង្គការ (ទំព័រ ៨៥២) ។ Guskey's (២០០២) បញ្ជាក់ពីខ្លឹមសារដូចគ្នានៃពាក្យថា" ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន គឺជាការខិតខំជាប្រព័ន្ធដើម្បីនាំមកនូវការផ្លាស់ប្តូរការអនុវត្តថ្នាក់

រៀនរបស់គ្រូ ក្នុងឥរិយាបថ និងជំនឿរបស់ពួកគាត់និងលទ្ធផលនៃការសិក្សារបស់សិស្ស" (ទំព័រ ៣៨១) ។ វាគឺជាចរិតលក្ខណៈ ដែលបង្កើតជាមូលដ្ឋានគ្រឹះនៃការយល់ដឹងអំពីការអភិវឌ្ឍន៍វិជ្ជាជីវៈរបស់គ្រូដែលត្រូវប្រើក្នុងការសិក្សានេះ។ ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូ គឺមានភាពស្មុគស្មាញក្នុងបរិបទផ្សេងៗ។ Desimone (ឆ្នាំ ២០០៩) ពន្យល់ពីវិធីមួយនៃដែនកំណត់នៃការលើការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូ គឺការយល់ដឹងនិងគំនិតមួយចំនួន ដែលទាក់ទងនឹងការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូដែលមានសកម្មភាព ផ្ដាច់មុខដូចជាសិក្ខាសាលា និងវគ្គសិក្សាផ្សេងៗ។

## ២.៣. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

តាមពិតការកំណត់បញ្ញត្តិ ឬការឱ្យនិយមន័យស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមានច្រើនណាស់។ ជូនកាលគេសរសេរពាក្យ នៅក្នុងឈ្មោះផ្សេងៗគ្នាប៉ុន្តែគេឱ្យនិយមន័យដូចគ្នា។ ដូចនេះបញ្ញត្តិធំៗបីនៃស្តង់ដាគ្រូបង្រៀនគឺ៖ (ក). ជាសេចក្តីអធិប្បាយសង្ខេប និងច្បាស់លាស់ នូវទិដ្ឋភាពទាំងឡាយណា ដែលគ្រូបង្រៀនត្រូវយល់ដឹង និងធ្វើ។ (ខ). ជាការបញ្ជាក់ប្រាប់ពីអំពើ ឬសកម្មភាពរបស់គ្រូបង្រៀនដែលអាចអនុវត្តបានហើយមានឥទ្ធិពលទៅលើសិស្ស។ (គ). ជាឧបករណ៍សម្រាប់វាស់សមត្ថភាពដែលស្តែងចេញរបស់គ្រូបង្រៀន។

ការកសាងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គឺមិនមែនមានបំណងវាយតម្លៃសមត្ថភាពរបស់គ្រូបង្រៀនដើម្បីចាត់ ជាប្រភេទគ្រូល្អ ឬគ្រូខ្សោយនោះទេ ពោលគឺមានគោលបំណងលើកស្ទួយការបង្រៀន និងរៀនរបស់គ្រូបង្រៀន សម្រាប់ជួយសម្រួលការសិក្សារបស់សិស្សឱ្យទទួលបានលទ្ធផលការសិក្សាដែលមានកម្រិតសមស្របដែលអាចទទួលយកបាន បើប្រៀបធៀបទៅនិងស្តង់ដា កម្មវិធីសិក្សាចំណោះទូទៅ។ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនជាឧបករណ៍ដ៏មានសារៈសំខាន់បំផុត និងជាខ្នាតគំរូសម្រាប់អ្នកអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូ និងសម្រាប់ធ្វើផែនការ កសាងសមត្ថភាពគ្រូបង្រៀន។ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ត្រូវមានសមភាពចំនួន **៤** មានដូចខាងក្រោម៖ (១). **ចំណេះដឹងវិជ្ជាជីវៈ** គ្រូបង្រៀនមានចំណេះដឹងវិជ្ជាជីវៈសំបូរបែប។ គាត់ត្រូវតែដឹងច្បាស់ពីតម្រូវការសិក្សា សមត្ថភាពសិក្សា ប្រវត្តិការសិក្សាច្បាស់លាស់ និងឥរិយាបថរបស់សិស្សម្នាក់ៗហើយក៏យល់ដឹងផងដែរ ពីប្រភេទគ្រួសារ និងកត្តាផ្សេងៗ ដែលមានឥទ្ធិពល

ដល់ការសិក្សារបស់សិស្ស (យេនឌ័រ ពិការភាព និងក្រុមជនជាតិភាគតិច...) ព្រមទាំងយល់ដឹងពីដំណោះស្រាយពីកត្តាទាំងនេះ។ គ្រូបង្រៀនត្រូវមានការយល់ដឹងពីគោលនយោបាយអប់រំ ជាពិសេសគោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះដឹងទូទៅហើយពេញចិត្តក្នុងការអនុវត្តនៅសាលារៀន។ គ្រូបង្រៀនយល់ដឹងពីទ្រឹស្តីក្នុងការរៀបចំកិច្ចតែងការបង្រៀន ដូចជាវត្ថុបំណង វិធីសាស្ត្របង្រៀន និងអាចជ្រើសរើសវិធីវាយតម្លៃលទ្ធផលសិក្សាបានសមស្រប។ គ្រូបង្រៀនយល់ដឹងខ្លឹមសារកម្មវិធិសិក្សាហើយមានសមត្ថភាពពន្យល់មេរៀនបានច្បាស់លាស់ និងយល់ពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយ ទៅមុខវិជ្ជាមួយផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន។ គ្រូបង្រៀនត្រូវយល់ដឹងពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងសហគមន៍ ពិសេសយល់ពីរបៀបរៀនរបស់សិស្សភាពខុសគ្នា រវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សាដែលមានឥទ្ធិពល ដល់ការសិក្សារបស់សិស្ស។ (២). **ការប្រតិបត្តិវិជ្ជាជីវៈ** គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀន ឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាព ស្របតាមកម្មវិធីសិក្សា ដោយផ្អែកលើសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារសិក្សាផ្សេងៗទៀតដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវរៀបចំសម្ភារបង្រៀន និងរៀនដើម្បីរិះរកមធ្យោបាយសម្រេចការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព។ គ្រូបង្រៀនក៏ប្រើប្រាស់វិធីវាយតម្លៃលទ្ធផលសិក្សាផ្សេងៗគ្នាដែលស្របទៅតាមតម្រូវការ និងទេពកោសល្យរបស់សិស្ស។ គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាលអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។ គ្រូបង្រៀនផ្តល់ឱ្យសិស្សគ្រប់រូបនូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាព ហើយលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចូលរួមក្នុងការអភិវឌ្ឍសាលារៀន ដើម្បីគាំទ្រការសិក្សា និងសុខុមាលភាពរបស់សិស្ស និងគ្រូបង្រៀនទៀត។ គ្រូបង្រៀន ត្រូវចេះប្រើប្រាស់វិធីបង្រៀនឱ្យសម្បូរបែប ដើម្បីសម្រួលដល់ការសិក្សារបស់សិស្សនិងសម្រេចបានវត្ថុបំណងមេរៀន។ ម្យ៉ាងទៀតគ្រូបង្រៀនគួរមានសមត្ថភាពផ្តល់ជាមធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្សតាមរយៈការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែប ដោយបង្កឱកាសឱ្យសិស្សចូលរួមគិត

បានល្អិតល្អន់ និងដោយថ្នៃប្រឌិត។ លើសពីនេះទៅទៀត គ្រូបង្រៀនត្រូវចេះប្រើប្រាស់បច្ចេកទេសវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធានក្នុងបណ្ណាល័យបើមានលទ្ធភាពដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។ (៣). **ការសិក្សាវិជ្ជាជីវៈ** យើងបានដឹងហើយថាគ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួល បានជោគជ័យ ក្នុងការសិក្សា។ដូច្នេះគាត់ត្រូវស្វ័យសិក្សា វាយតម្លៃការបង្រៀន ដើម្បី អភិវឌ្ឍខ្លួនឯង និងប្រើប្រាស់ ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាមុខវិជ្ជាជីវៈជាប្រចាំស្របតាម ជីវភាពរស់នៅជាក់ស្តែង។គ្រូបង្រៀនត្រូវ អភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យ ប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតា មិត្តរួមអាជីប និងជាមួយអ្នកផ្សេងៗទៀត នៅក្នុង សហគមន៍។ គ្រូបង្រៀនត្រូវលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈកាតអាន និងស្រាវជ្រាវ ប្រភពឯកសារផ្សេងៗ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលំអការបង្រៀន និងរៀន ហើយ ត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀតក្នុងការសិក្សាវិជ្ជាជីវៈ។(៤).**សីលធម៌វិជ្ជាជីវៈ** សីលធម៌វិជ្ជាជីវៈ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀនដែលជារួមមានការ ប្តេជ្ញាចិត្ត បង្រៀនសិស្សប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបដោយគតិបណ្ឌិត និង មានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។ គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងសាលារៀន មានការស្លៀកពាក់ សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ។គាត់គួរតែចូលរួមក្នុងគ្រប់សកម្មភាព ទាំងក្នុង និងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើបាន។ គ្រូបង្រៀនមានប្រសិទ្ធភាព គឺមិនរើសអើងសិស្ស ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ដូចជាបញ្ហា យេនឌ័រ ជនជាតិភាគតិច ពិការភាព ក្រីក្រ និងត្រូវចេះថែទាំសិស្ស ផ្តល់លទ្ធភាព ឱ្យសិស្សប្រើប្រាស់ធនធាន ឱ្យអស់ពីលទ្ធភាព ហើយយកចិត្តទុកដាក់ដល់សិស្សឱ្យបានស្មើៗគ្នា រួចបង្ហាញពីភាពយុត្តិធម៌ក្នុងការត្រួតពិនិត្យ លទ្ធផលសិក្សា។នៅពេលទាក់ទងជាមួយសិស្ស គ្រូបង្រៀនត្រូវមានការគោរពសិស្សដោយមិននិយាយមើលងាយ ឬដាក់ទណ្ឌកម្មពួកគេតាមរបៀបហឹង្សាឡើយ។គ្រូបង្រៀនប្រកាន់ចរិយាសម្បត្តិមានសុជីវធម៌ និងអាកប្បកិរិយាថ្លៃថ្នូរ សម្រាប់ធ្វើការសហការជាមួយសហការី និងមាតាបិតាសិស្សដើម្បីផលប្រយោជន៍

សិស្សផ្ដល់ជាគំរូដល់សិស្ស ក្នុងការរស់នៅ និងរៀនសូត្របានល្អ ពិសេសចេះលើកកម្ពស់ស្មារតីសិស្សឱ្យរឹងប៉ឹង និងវិជ្ជមានហើយបង្កើត ស្មារតីលះបង់ និងការរួមចំណែកចំពោះសហគមន៍ទាំងមូល។

## ២.៤. លក្ខណៈសម្បត្តិរបស់គ្រូបង្រៀនក្នុងសតវត្សទី២១

បើយោងតាមការវិវត្តន៍នៃពិភពលោកតាមរយៈការធ្វើ ឱ្យមាននូវសាកលភាវូបនីយកម្មលើគ្រប់ផ្នែកទាំងបច្ចេកវិទ្យាពាណិជ្ជកម្ម និងការអប់រំក្នុងសម័យបច្ចេកវិទ្យានេះផងដែរ នោះគ្រូបង្រៀនគប្បីប្រកបទៅដោយលក្ខណៈសម្បត្តិពិសេសចាំបាច់៖ ៖(ក).**ចំណេះដឹងឯកទេសវិជ្ជាជីវៈ ៖** គ្រូបង្រៀនជាបុគ្គល ដែលនៅផ្ទាល់ជាមួយសិស្ស ជាអ្នកផ្ទេរចំណេះដឹងដល់សិស្សនិងជាអ្នកកសាងធនធានមនុស្សសម្រាប់បម្រើឱ្យសេចក្ដីត្រូវការរបស់សង្គម ក្នុងការអភិវឌ្ឍសង្គមជាតិមួយដែលពោពេញទៅដោយសុខសន្តិភាព និងរីកចម្រើនដោយចីរភាព។មានចំណេះដឹងច្បាស់លាស់ លើមុខវិជ្ជាឯកទេសមានសារៈសំខាន់ណាស់ ក្នុងការធ្វើឱ្យសិស្សទទួលបានសមត្ថភាពពិតប្រាកដ និងមានលក្ខណៈវិទ្យាសាស្ត្រដែលអាចធ្វើឱ្យការសិក្សារបស់សិស្សទទួលបានជោគជ័យ តាមរយៈសកម្មភាពសិក្សាយ៉ាងរស់រវើកនិងសម្រេចតាមវត្ថុបំណងឬស្តង់ដាកម្មវិធីសិក្សាកំណត់។(ខ).**មានចំណេះដឹងទូលំលាយ ៖** គ្រូបង្រៀនទាមទាឱ្យមានចំណេះដឹងច្រើនដែលទាក់ទង និងការបំពេញការងារប្រចាំថ្ងៃគឺការបង្រៀន។ជាការពិតណាស់ ការបង្រៀនត្រូវមានជារួមបញ្ចូលនូវការអនុវត្តជាក់ស្ដែងទាក់ទង និងជីវៈភាពរស់នៅក្នុងសង្គម។ឧទាហរណ៍«**ដាំនៅសាលាផ្លែផ្កានៅក្នុងសង្គម**»ត្រូវឲសិស្សចេះគិតផ្ទៃដីជាការ៉េ រករង្វាស់ដីគិតជាអានិងឱ្យសិស្សចេះរកផ្ទៃជញ្ជាំងនិងរកផ្ទៃបាតសំខាន់ឱ្យសិស្សចេះរកប្រាក់ចំណាយនីមួយៗ។ ម៉្យាងវិញទៀតត្រូវបញ្ចូលអ្វីដែលមានប្រយោជន៍ ដល់ការអភិវឌ្ឍបញ្ញាស្មារតី របស់សិស្សដែលជាកត្តាចម្បងដើម្បីជំនួយក្នុងការចងចាំមេរៀនបានល្អ និងយូរអង្វែង។មានចំណេះដឹងទូទៅ ទាក់ទងនិងបរិបទសង្គមពិតជាមានប្រយោជន៍ សម្រាប់សិស្សក្នុងការពង្រឹងពុទ្ធិដើម្បីធ្វើស្វ័យអភិវឌ្ឍន៍បំណិនផ្សេងៗ ក្នុងការត្រិះរិះពិចារណាប្រកបដោយភាពស៊ីជម្រៅនិងជាមូលដ្ឋានគ្រឹះក្នុងការសម្រេចចិត្តបានត្រឹមត្រូវថែមទៀតផង។ (គ).**មានបំណិនក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀន ៖** ការបង្រៀន ក្នុងថ្នាក់មួយប្រាកដជា មានបញ្ហាប្រឈមទៅ នឹងបញ្ហាផ្សេងៗ ជាក់ជាមិនខានជាពិសេសកត្តាសមត្ថភាពសិស្ស មិនស្មើគ្នានេះជាបញ្ហាចម្បងជាងគេ ដែលគ្រូបង្រៀនម្នាក់ៗ ត្រូវរិះរកវិធី

សាស្ត្រដោះស្រាយ ដើម្បីឱ្យសិស្សទទួលបានចំណេះដឹងដូចៗគ្នា។ ក្នុងន័យនេះមានន័យថាគ្រូបង្រៀនត្រូវតែដឹងអំពីសមត្ថភាពរបស់សិស្សម្នាក់ៗ ហើយត្រូវមានល្បិចផ្សេងៗ បែបវិទ្យាសាស្ត្រដើម្បីសម្រេចឱ្យបានវត្ថុបំណងមេរៀន។ការប្រើប្រាស់វិធីសាស្ត្រ ឬយុទ្ធសាស្ត្រក្នុងការបង្រៀនត្រូវទាមទារ ឱ្យមានភាពប៉ិនប្រសប់ប្រកបដោយ ភាពរហ័សរហួននៅពេលដែល ដឹងថាវិធីដែលគាត់បានប្រើក្នុងការបង្រៀននោះមិនទទួលបានផលល្អនោះ។(**ឃ**).**មានចំណេះដឹងលើកម្មវិធីសិក្សា ៖** ការអនុវត្តកម្មវិធីសិក្សាមានសារៈសំខាន់ណាស់ ដើម្បីឱ្យការរៀននិងបង្រៀនអាចសម្រេចបានតាមស្តង់ដាកំណត់ នៃមុខវិជ្ជានីមួយៗតាមកម្រិតថ្នាក់។ គ្រូបង្រៀនចាំបាច់ត្រូវស្គាល់ថា អ្វីទៅជាកម្មវិធីសិក្សានិងគោលបំណងនៃកម្មវិធីក៏ដូចជារិះរកនូវអវិជ្ជាមានឬបញ្ហាប្រឈមផ្សេងៗដែលបានជួបប្រទះ ក្នុងការអនុវត្តកម្មវិធីសិក្សាដើម្បីធ្វើការកែលម្អឱ្យកម្មវិធីសិក្សាមានប្រសិទ្ធភាពនិងភាពឆ្លើយតប។ **(ង).ចំណេះដឹងក្នុងការកសាងតេស្តវាយតម្លៃ ៖** ការវាស់ស្ទង់ចំណេះដឹង របស់សិស្សជាប្រចាំ គឺជាការកិច្ចរបស់គ្រូបង្រៀនដើម្បីដឹងថាការផ្ទេរចំណេះដឹង ពីគ្រូសិស្សទទួលបានកម្រិតណា និងដើម្បីធ្វើការវាយតម្លៃ លទ្ធផលសិក្សារបស់សិស្ស។ គ្រូបង្រៀនត្រូវមានបំណិន ក្នុងការកសាងតេស្តឬវិញ្ញាសាប្រឡងសម្រាប់សិស្សប្រកបដោយលក្ខណៈវិទ្យាសាស្ត្រនិងសមស្របទៅតាមទ្រឹស្តីរបស់លោកប្លូម (BLOOM TAXONOMY,1956)មានប្រាំមួយកំម្រិតគឺ ចងចាំ យល់ អនុវត្ត វិភាគវាយតម្លៃនិងការបង្កើតថ្មី។ត្រូវចេះផ្ទេរចំណេះដឹងទៅឱ្យត្រូវកម្រិតសមត្ថភាពសិស្ស ពីកម្រិតទាប ចងចាំ ទៅកម្រិតខ្ពស់ការបង្កើតថ្មី។ចៀសវាងការកសាងតេស្តដោយមិនមានភាពត្រឹមត្រូវសមស្របទៅ និងសមត្ថភាពរបស់សិស្ស។ **(ច).មានចំណេះដឹង ភាសាបរទេស និងព័ត៌មានវិទ្យា** ICT នៅក្នុងសម័យសាកលភាវូនីយកម្ម និងបច្ចេកវិទ្យាទំនើបប្រព័ន្ធព័ត៌មានវិទ្យា មានសារៈសំខាន់ណាស់សម្រាប់បម្រើ ឱ្យការរស់នៅរបស់មនុស្ស។បើនិយាយទៅដល់ការសិក្សាស្រាវជ្រាវវិញនោះ ភាសាអង់គ្លេស និងICT បានដើរតួរចម្បងសម្រាប់ស្វែងរកនូវឯកសារផ្សេងៗ ដែលបានធ្វើទំនើបកម្មពាសពេញពិភពលោក។គ្រូបង្រៀនត្រូវទាមទារឱ្យធ្វើការសិក្សាស្រាវជ្រាវជាប្រចាំ ដើម្បីធ្វើការអភិវឌ្ឍសមត្ថភាពចំណេះដឹងឯកទេសរបស់ខ្លួន ឱ្យសមស្របទៅនឹងការអភិវឌ្ឍនៃបរិបទអប់រំក្នុងពេលបច្ចុប្បន្ន។ **(ឆ).មានបំណិនក្នុងការប្រាស្រ័យទាក់ទង និងដោះស្រាយ** មានប្រាស្រ័យទាក់ទងនិងអ្នកជុំវិញខ្លួន គឺជាផ្នែកមួយដើម្បីទទួល

បានការគាំទ្រពីសហគមន៍និងមាតាបិតាអាណាព្យាបាលសិស្សដែលជាផ្នែកមួយដ៏សំខាន់ ក្នុងការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងវិស័យអប់រំ។ គ្រូបង្រៀនក៏ទាមទាឱ្យមានបំណិនក្នុងការដោះស្រាយបញ្ហាផងដែរ ដែលបានកើតឡើងក្នុងពេលបង្រៀនដោយឈរលើស្មារតីសាមគ្គីភាពតម្លាភាពនិងសមធម៌។

## ២.៥. គំណែនម្រង់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនរបស់ក្រសួងអប់រំ

### ២.៥.១. គោលនយោបាយស្តីពីគ្រូបង្រៀន

គោលនយោបាយស្តីពីគ្រូបង្រៀន (ឆ្នាំ២០១៣) បានដាក់ចេញ នូវចក្ខុវិស័យគោលបំណងនិងគោលដៅសំខាន់ៗ ៖(ក).**ចក្ខុវិស័យ** ៖ កសាងគ្រូបង្រៀនឱ្យមានចំណេះដឹងជំនេញសីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈដោយមានការទទួលពីសង្គម។ (ខ).**គោលបំណង ៖** អភិវឌ្ឍគ្រូបង្រៀន ឱ្យមានគុណភាពសមត្ថភាពស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់ក្របខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព ។(គ). **គោលដៅ** ៖ (១).ទាក់ទាញ និងលើកកម្ពស់អ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវគ្រូបង្រៀន (២).ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន (៣). ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងការបម្រើការងារជាប់ជាប្រចាំ។ (៤).ធានាលក្ខខ័ណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និង ភាពសក្តិសិទ្ធ។

#### យុទ្ធសាស្ត្រ

ដើម្បីសម្រេចគោលដៅនៃគោលនយោបាយស្តីពីគ្រូបង្រៀន ក្រសួងអប់រំយុវជន និងកីឡាបានដាក់ចេញយុទ្ធសាស្ត្រសំខាន់ៗចំនួន៩ និងយុទ្ធសាស្ត្ររងចំនួន៣៤។ **យុទ្ធសាស្ត្រទាំង៩រួមមាន៖ យុទ្ធសាស្ត្រទី១.** កសាងលិខិតបទដ្ឋានគតិយុទ្ធ និងយន្តការ **យុទ្ធសាស្ត្រទី២.** ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈគ្រូបង្រៀន **យុទ្ធសាស្ត្រទី៣.** កំណត់ស្តង់ដាបណ្តុះបណ្តាលគ្រូបង្រៀន **យុទ្ធសាស្ត្រទី៤.** អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន **យុទ្ធសាស្ត្រទី៥.** ធ្វើសទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា **យុទ្ធសាស្ត្រទី៦.** អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ **យុទ្ធសាស្ត្រទី៧.** លើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន **យុទ្ធសាស្ត្រទី៨.** ពង្រឹងប្រសិទ្ធភាពជាអ្នកដឹកនាំសាលារៀន **យុទ្ធសាស្ត្រទី៩.** ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគ្រូបង្រៀន

**ផែនការសកម្មភាព**

នៅក្នុងយុទ្ធសាស្ត្រទី២ មានផែនការសកម្មភាពដូចជា៖ (១). លើកកម្ពស់ជីវៈភាពតម្លៃវិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ពីសង្គម (២). លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន (៣). កំណត់លក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់គ្រូ (៤). ធ្វើទំនើបកម្មស្តង់ដាកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ឱ្យឆ្លើយតបទៅនិងតម្រូវការរបស់ជាតិ និងការប្រកួតប្រជែងក្នុងតំបន់និងសកលលោក។ នៅក្នុងយុទ្ធសាស្ត្រទី៦ មានផែនការសកម្មភាពដូចជា៖(១).បណ្តុះវប្បធម៌ រៀនពេញពេញមួយជីវិតដោយចេះចែករំលែកបទពិសោធន៍ជាមួយបណ្តាញ ក្រុម អ្នកអប់រំ។ (២). រៀនចំយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រគ្រូបង្រៀននៅនឹងកន្លែងធ្វើការ។ (៣).រៀបចំគោលការណែនាំស្តីពីតម្រូវការ និងផលប្រយោជន៍នៃគោលការអភិវឌ្ឍវិជ្ជាជីវៈ។

## ២.៥.២. កំណែទម្រង់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន

តាមការសន្និបាតអប់រំចក្ខុវិស័យនៃកំណែទម្រង់វិស័យអប់រំ នៅកម្ពុជា ២៤ ខែមីនា ឆ្នាំ២០១៥ បានដាក់ចេញកំណែទម្រង់ដូចខាងក្រោម៖(១). ការបណ្តុះបណ្តាលវប្បធម៌រៀនពេញមួយជីវិត ដោយចែករំលែកបទពិសោធន៍ ជាមួយបណ្តា ញក្រុមអ្នក អប់រំ និងបង្កើនគុណវុឌ្ឍិគ្រូបង្រៀនដោយទទួលបានសញ្ញាបត្រ តាមរយៈកម្ម វិធី ១ខែ កន្លះ បីបង។ (២). អភិវឌ្ឍន៍ និងការអនុវត្តការងារ វិក្រឹត្តការគ្រូបង្រៀន (ពង្រឹង ភាសាខ្មែរ គណិតវិទ្យា ប្រវត្តិ វិទ្យា និងវិទ្យាសាស្ត្រសម្រាប់គ្រូបង្រៀននៅថ្នាក់ទី៩ និងថ្នាក់ទី១២)។ (៣). បង្កើតប្រព័ន្ធវិក្រឹត្តការរៀបរយ ដោយអនុវត្តការងារវិក្រឹតការ៖ (ក) នៅនឹងកន្លែង (ខ)មិន រៀបរយតាមការចាំបាច់នៃវិស័យអប់រំ (គ)រៀបរយដែលមានប្រព័ន្ធកម្មវិធីត្រឹមត្រូវ។ (៤). ការបង្កើនគុណវុឌ្ឍិគ្រូឧទ្ទេសបណ្តុះបណ្តាលគ្រូឱ្យដល់កម្រិត យ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សា និងទទួលបានការគោរពនិងឱ្យតម្លៃពីសង្គម។

## ២.៥.៣. កំណែទម្រង់ជាអាទិភាពសម្រាប់ឆ្នាំ២០១៤-២០១៨

ក្រសួងអប់រំយុវជននិងកីឡាបានកំណត់កម្មវិធីកំណែទម្រង់ ជាអាទិភាពចំនួន១៥ចំណុចដើម្បី

កែលម្អវិស័យអប់រំឱ្យមានភាពប្រសើរឡើងវិញ និងអាចទទួលយកបាននូវលទ្ធផលល្អដែលអាចប្រកួតប្រជែងក្នុងបណ្តាលប្រទេសក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ។កំណែទម្រង់ជាអាទិភាពទាំង១៥ចំណុចរួមមាន៖ (១)កំណែទម្រង់ការគ្រប់គ្រងបុគ្គលិក(២) ការពង្រាយគ្រូបង្រៀន(៣). កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន(៤).ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន(៥). ការងារអធិការកិច្ច (៦)ការវាយតម្លៃលទ្ធផលសិក្សា (៧) កំណែទម្រង់ការប្រឡងគ្រប់ប្រភេទ (៨) កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល (៩) ការសាងសង់អាគាសិក្សា និងជួសជួល (១០) ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា (១១). ការលើកកម្ពស់វិស័យកីឡា (១២). ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន (១៣). ការអប់រំបច្ចេកទេស (១៤). ការបង្កើតសាលាជំនាន់ថ្មី (១៥). ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា (ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨) ។ **សរសេរស្តម្ភទាំងប្រាំនៃគុណភាពអប់រំ** ក្រសួងអប់រំយុវជន និងកីឡា បានកំណត់ចក្ខុវិស័យនៃកំណែទម្រង់វិស័យអប់រំនៅកម្ពុជាបានដាក់ចេញនូវសរសេរស្តម្ភចំនួនប្រាំ នៃគុណភាពអប់រំដើម្បីលើកម្ពស់ការងារគ្រប់គ្រងនិងរដ្ឋបាលកម្មវិធីសិក្សាការទទួលស្គាល់គុណភាពអប់រំផងដែរ។

**សរសេរស្តម្ភទាំងប្រាំរួមមាន៖**

**សរសេរស្តម្ភទី១៖**ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន

**សរសេរស្តម្ភទី២៖**ការធ្វើកំណែទម្រង់កម្មវិធីសិក្សា សៀវភៅសិក្សាគោលនិងបរិស្ថានសិក្សា

**សរសេរស្តម្ភទី៣៖**ការធ្វើអធិការកិច្ច

**សរសេរស្តម្ភទី៤៖**ការពង្រឹងវង្វាយតម្លៃការសិក្សា (ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ)

**សរសេរស្តម្ភទី៥៖** ការកំណែទម្រង់ឧត្តមសិក្សា

## ២.៥.៤. កំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៨-២០២៣

នៅក្នុង កំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៨-២០២៣ មាន៖ (១). រៀបចំយន្តការអនុវត្ត និងគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈ បុគ្គលិកអប់រំជាប្រចាំនៅគ្រឹះស្ថានបណ្តុះ បណ្តាលគ្រូដោយផ្តោតលើការបណ្តុះបណ្តាលនៅកន្លែង។(២).កំណត់ពេលដាក់លាក់ ដើម្បីធ្វើវិក្រឹតការគ្រូបង្រៀន។ (៣).

រៀបចំប្រព័ន្ធវាយតម្លៃ និងទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ លើសកម្មភាព អភិវឌ្ឍវិជ្ជាជីវៈ ដើម្បី ទទួលស្គាល់ជាផ្លូវការ ឬផ្តល់ជាសញ្ញាបត្រសមមូល។ (៤). រៀបចំប្រព័ន្ធអភិវឌ្ឍគុណវុឌ្ឍិបុគ្គលិកអប់រំគ្រប់រូបភាព (បំប៉ននៅនឹងកន្លែង កម្មវិធីពន្លឿន ឬវគ្គ បណ្តុះបណ្តាលខ្លីៗ សម្រាប់អ្នកមានសញ្ញាបត្រ)។ (៥). រៀបចំនិងអភិវឌ្ឍគោលការណ៍ណែនាំស្តីពីសហគមន៍សិក្សាវិជ្ជាជីវៈ ។

**កំណែទម្រង់ក្នុងវិស័យអប់រំ ២០១៩ - ២០២៣**

កំណែទម្រង់ការគ្រប់គ្រងការសិក្សា មាន (៦) គ្រូបង្រៀនរៀបចំ តេស្តចំណេះដឹង នឹងបំណិនរបស់សិស្ស ឱ្យមានសុគតិភាពជាមួយ នឹង ក្របខណ្ឌវង្វាយតម្លៃជាតិ។ (៧) គ្រូបង្រៀនប្រើប្រាស់ វិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីបង្កើនលទ្ធផលសិក្សា របស់សិស្សរួមមានការ សិក្សាគម្រោងដែលទាក់ទងទៅនឹងមុខវិជ្ជាអាទិភាពសម្រាប់សិស្សធ្វើជាបុគ្គលជាដៃគូឬជាក្រុម។ (៨) គ្រូបង្រៀនជួយសិស្ស រៀនឃើតជាប្រចាំ និងរៀបចំវិធីសាស្ត្របង្រៀននិងប្រព័ន្ធវាយតម្លៃ។ (៩) គ្រូបង្រៀនទទួលបានការបំប៉នលើវិធីសាស្ត្របង្រៀនបែបថ្មី(១០) ផលិតសម្ភារៈជំនួយការបង្រៀន និងអនុវត្តវិធីសាស្ត្របង្រៀនសមស្រប (១១) គ្រូបង្រៀនស្រាវជ្រាវវិធីសាស្ត្របង្រៀន ដើម្បីកែលម្អគុណភាពការបង្រៀន និងចូលរួមកម្មវិធី **អភិវឌ្ឍវិជ្ជាជីវៈ៖** ផ្លាសប្តូរវិធីសាស្ត្របង្រៀន ពីការរៀនបែបអកម្ម ដែលសិស្សជាអ្នករង់ចាំទទួលចំណេះដឹង ទៅជាវីធីសាស្ត្រថ្មី ឬការរៀនបែបសកម្ម ដែលសិស្សជាអ្នកបង្កើតនូ វចំណេះដឹងថ្មីៗ។ (១). បង្កើតសហគមន៍រៀនវិជ្ជាជីវៈដើម្បីចែករំលែកនូវការអនុវត្តល្អៗក្នុងការបង្រៀន។ (២). ការអនុវត្តបច្ចេកទេសគ្រប់គ្រងថ្នាក់រៀន ដើម្បីដឹងពីស្ថានភាពសិស្សច្បាស់លាស់។ (៣). ធានាឱ្យសិស្សចេះប្រើទស្សនៈចេះវិភាគ ដោះស្រាយបញ្ហា និងចេះធ្វើការជាក្រុម (៤) ប្រើបច្ចេកវិទ្យាព័ត៌មាន (អ៊ីម៉ែល និងអ៊ិនធឺណែត) ដើម្បីលើកកម្ពស់វិធីសាស្ត្ររៀនថ្មី ការរៀន តាមបែបសហការ (ឧទាហរណ៍ បណ្តាញទំនាក់ទំនង)បង្កើត និងសំយោគព័ត៌មានថ្មីៗ (៥) បទបង្ហាញ (Power Point) ដោះស្រាយបញ្ហា (ឧទាហរណ៍ កម្មវិធីដំណើរការទិន្នន័យ ដែល អាចបង្ហាញ ភាពខុសគ្នាទិន្នន័យតម្រៀប ។ល។) និងវិធីសន្ទនាការពិភាក្សា និងការជជែក វែកញែក ដែលនាំឱ្យមាន ការស្ថាបនាសង្គម។ (៦) អនុវត្តន៍សកម្មភាពសំណួរ ចម្លើយ ដើម្បីជួយសិស្សឱ្យឆ្លុះបញ្ចាំងពី បទពិសោធន៍ និងបរិបទថ្មីៗ ដើម្បី

កសាងនូវគំនិតថ្មីមួយអាចដោះស្រាយបញ្ហាជីវិតជាក់ស្តែង។ (៧) ផ្តោតលើការបង្រៀនជំនាញការគិតទ្រឹស្តីBloom រួមមានការវិភាគ ការសំយោគ និងការវាយតម្លៃ (៨) រំញោចសិស្សឱ្យផ្លាស់ប្តូរគំនិត តាមរយៈការពិភាក្សា លើកទឹកចិត្តសិស្សឱ្យចេះសំ យោគ គំនិតតែមួយគត់។ (៩) លើកទឹកចិត្តសិស្សឱ្យរៀបចំបទបង្ហាញ Power Point ជាក្រុម ដែលមានសារៈប្រយោជន៍ដល់ សិស្សធ្វើ ការជាមួយគ្នាប្រកបដោយភាពច្នៃប្រឌិត និងចែករំលែកដល់សិស្សក្នុងថ្នាក់។(១០) កែលម្អវិធីសាស្ត្របង្រៀន ដូចជាការដើរតួដើម្បីធានាថាសិស្សទទួលបានចំណេះដឹងលើបញ្ហាសកល (១១) ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍ឌីជីថលដើម្បីអនុវត្តកម្មវិធីសិក្សាភាពជាពលរដ្ឋ (១២) បង្រៀនបែបសិស្សគម្រោង និងធ្វើការបំផុសគំនិត ឱ្យអនុវត្តកម្មវិធីសិក្សា ភាពជាពលរដ្ឋមាន គុណភាព (១៣) លើកទឹកចិត្តសិស្សឱ្យរៀបចំសម្ភារៈសិក្សា ស្របតាមបរិបទភាពជាពលរដ្ឋ មានគុណភាព ដែល ត្រូវធ្វើបទ បង្ហាញ មានរូបភាព ក្រាហ្វិច គំនូសតាង និងដ្យាក្រាម។ (១៤) រៀបចំ ការប្រឡងសំណេរ ក្រោមប្រធានបទពាក់ព័ន្ធ និងបញ្ហាប្រឈមនានាលើភាព ជាពលរដ្ឋប្រកបដោយគុណភាព

## ២.៦. វិទ្យាស្ថានជាតិអប់រំ

វិទ្យាស្ថានជាតិអប់រំ (វជអ) និងជាភាសាអង់គ្លេស National Institute of Education (NIE) ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដ៏សំខាន់មួយ ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈជាច្រើន ដែលបានបំពេញតួនាទីក្នុងការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យអប់រំ តាំងពីឆ្នាំ១៩១៤មកម្ល៉េះ។ វិទ្យាស្ថានជាតិអប់រំ មានទស្សនៈវិស័យ និងមានភារកិច្ចបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបម្រើសេចក្តីត្រូវការនៃការអភិវឌ្ឍសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេសចូលរួមយ៉ាងសកម្មក្នុងកំណែទម្រង់ទាំងឡាយដែលទាក់ទងនឹងកំណែទម្រង់គ្រូបង្រៀន មន្ត្រីគ្រប់គ្រងអប់រំ ការបណ្តុះបណ្តាលនាយក និងការពង្រឹងសមត្ថភាពអធិការជាដើម។ អ្នកដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថាននេះ រួមមានមន្ត្រី បុគ្គលិក សាស្ត្រាចារ្យ គ្រូបង្រៀន អ្នកស្រាវជ្រាវ អ្នកវាយតម្លៃ និងអ្នកសិក្សាគ្រប់កម្រិតរួមទាំងគ្រូពន្លឿនកម្រិតមូលដ្ឋានឆ្ពោះទៅរកបរិញ្ញាបត្រ។ ការបណ្តុះបណ្តាលគ្រូពន្លឿននេះ គឺត្រូវបានបណ្តុះបណ្តាលពីលោកគ្រូអ្នកគ្រូ និងសាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិអប់រំផ្ទាល់។ សាស្ត្រាចារ្យនៅវិទ្យា

ស្ថានជាតិអប់រំ ជាសាស្ត្រាចារ្យមានបទពិសោធន៍យូរឆ្នាំ មានកម្រិតវប្បធម៌ខ្ពស់ក្នុងការបណ្តុះបណ្តាល ហើយភាគច្រើនជាបណ្ឌិត និងអនុបណ្ឌិតទាំងក្នុង និងក្រៅប្រទេស។ គណៈគ្រប់គ្រង បុគ្គលិក គ្រូឧទ្ទេស និងគ្រូបង្រៀនចំនួន ២៣៧នាក់ (ស្រី៩៧នាក់) បានចែកចេញទៅតាមកម្រិតសញ្ញាបត្រដូចខាងក្រោម៖

**តារាងទី ២.១. តារាងស្ថិតិគ្រូនៅ វិទ្យាស្ថានជាតិអប់រំ**

| បណ្ឌិត | | អនុបណ្ឌិត | | បរិញ្ញាបត្រ | | ក្រោមបរិញ្ញាបត្រ | |
|---|---|---|---|---|---|---|---|
| សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ០៦ | ០០ | ១៣៧ | ៤៩ | ៦០ | ២២ | ៣២ | ២៦ |

ចាប់ពីឆ្នាំ១៩៧៩ មកដល់ឆ្នាំ១៩៩៣ វិទ្យាស្ថានជាតិអប់រំបានធ្វើការបណ្តុះបណ្តាល និងបើកវគ្គវិក្រឹតការសម្រាប់បំប៉នមុខជំនាញបច្ចេកទេសគរុកោសល្យ ការងារគ្រប់គ្រង និងជំនាញផ្សេងៗទៀតពាក់ព័ន្ធនឹងការងារអប់រំដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ក្នុងទូទាំងប្រទេសបានចំនួន ៣០០០០នាក់ និង ចាប់ពីក្រោយឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ២០១៦ វិទ្យាស្ថានជាតិអប់រំបានធ្វើការបណ្តុះបណ្តាលមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់បានចំនួន១៦៨៣៧នាក់ (ស្រី៤៨០៥នាក់)។ ២០១៧ ដល់ ២០១៨ បានបណ្តុះបណ្តាលគ្រូភាសា ខ្មែរ បារាំង មន្ត្រីអប់រំ និងបរិញ្ញាបត្រ + ១ បានចំ ២០០១នាក់ ស្រី ៧១៦នាក់។ ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩ បានបណ្តុះបណ្តាលគ្រូពន្លឿនទាំង៣ជំនាន់ទូទាំងប្រទេសមានចំនួន ២,៦៨៤នាក់ ស្រីមាន ៩៣៥ នាក់។

**តារាងទី ២.២. ចំនួនគ្រូពន្លឿនដែលបានទទួលការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំ**

| លរ | គ្រូពន្លឿនទទួលការបណ្តុះបណ្តាលនៅវេជអ | សរុបចំនួន | ស្រី |
|---|---|---|---|
| ១ | គ្រូពន្លឿនវគ្គ១ ឆ្នាំសិក្សា២០១៦-២០១៧ | ៦៩១នាក់ | ១៩៨នាក់ |
| ២ | គ្រូពន្លឿនវគ្គ២ ឆ្នាំសិក្សា២០១៧-២០១៨ | ៩៨៨នាក់ | ៣៥០នាក់ |
| ៣ | គ្រូពន្លឿនវគ្គ៣ ឆ្នាំសិក្សា២០១៨-២០១៩ | ១០០៥នាក់ | ៣៨៧នាក់ |
| | សរុប | ២,៦៨៤នាក់ | ៩៣៥នាក់ |

ប្រភព៖ របាយការណ៍របស់វិទ្យាស្ថានជាតិអប់រំឆ្នាំ២០១៩

## ២.៧. កម្មវិធីពន្លឿន

ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រពន្ធ័ពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រ ដោយប្តូរក្របខណ្ឌពីគ្រូកម្រិតមូលដ្ឋាន ទៅជាគ្រូបង្រៀនកម្រិតឧត្តម នៅវិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា។ការបណ្តុះបណ្តាលសំដៅដល់ គ្រូបង្រៀនដែលកំពុងបង្រៀននៅតាមវិទ្យាល័យ សម្រាប់បីវគ្គចាប់ពីវគ្គ ឆ្នាំ២០១៥-២០១៦ ២០១៦-២០១៧ ដល់វគ្គ ឆ្នាំ២០១៧-២០១៨ និងវគ្គបន្តបន្ទាប់ទៀត។

លក្ខខណ្ឌនៃការបណ្តោះបណ្តាល និងការជ្រើសរើសនិស្សិត ឱ្យចូលរៀនវគ្គគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រពន្ធ័ពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រ។បង្កើនសមត្ថភាពដល់បុគ្គលិកអប់រំ ដែលជាគ្រូបង្រៀនកម្រិតមូលដ្ឋានឱ្យក្លាយជាគ្រូបង្រៀនកម្រិតបរិញ្ញាបត្រតាមប្រពន្ធ័ពន្លឿន។

លក្ខខណ្ឌនៃការជ្រើសរើសចូលរៀន គឺបេក្ខជន ដែលអាចអនុញ្ញាតឱ្យចូលរៀនវគ្គបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រពន្ធ័ពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញបត្រ ត្រូវបំពេញលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖ (១). ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន (២). ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើស ឬដោយគណៈកម្មាធិការជ្រើសរើស (៣). ត្រូវគោរពតាមលក្ខខណ្ឌផ្សេងទៀត ស្របតាមគោលនយោបាយរបស់ក្រសួងអប់រំយុវជននិងកីឡា (៤). វិទ្យាស្ថានជាតិអប់រំ ត្រូវរៀបចំសេចក្តីជូនដំណឹងសម្រាប់ជ្រើសរើស និងលក្ខខណ្ឌលម្អិតផ្សេងទៀត សម្រាប់ ជ្រើសរើសនិស្សិតតាមឆ្នាំសិក្សានីមួយៗ។

កម្មវិធីនៃការបណ្តុះបណ្តាល ត្រូវមានភាពបត់បែនតាមសមត្ថភាពបេក្ខជន ក្រោយពេលប្រឡងជាប់ ដោយអនុវត្តតាមកម្មវិធីពន្លឿន៦០ ក្រេឌីត។ បេក្ខជនដែលប្រឡងជ្រើសរើសជាប់ ត្រូវឆ្លងកាត់ការវាយតម្លៃលើកម្រិតសញ្ញាបត្រ វិញ្ញាបនបត្របទពិសោធន៏ការងារ និង គ្រឿងឥស្សរិយយសការងារ ដើម្បីកំណត់ចំនួនក្រេឌីតជាក់លាក់ ក្នុងការបណ្តុះបណ្តាល។

និស្សិតដែលបានបំពេញគ្រប់លក្ខខណ្ឌនៃការបណ្តុះបណ្តាល ទទួលបានសញ្ញាបត្រមានតម្លៃសមមូលនិងសញ្ញាបត្របរិញ្ញាអប់រំ តាមជំនាញឯកទេសនីមួយៗ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។វិទ្យាស្ថានជាតិអប់រំ ត្រូវរៀបចំបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាស្ថានពរ

ដើម្បីសុំការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។ វិទ្យាស្ថានអប់រំ ត្រូវរៀបចំការប្រឡងបញ្ចប់ការសិក្សារបស់និស្សិត នៅពេលបញ្ចប់កម្មវិធីបណ្តុះបណ្តាលនីមួយៗ។ការចំណាយសម្រាប់ដំណើរការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន តាមប្រពន្ធ័ពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រ ត្រូវប្រើប្រាស់ថវិកាជាតិក្នុងគម្រោងរបស់ក្រសួងអប់រំ យុវជន និងកីឡានិងថវិកាដៃគូអភិវឌ្ឍន៏។

## ២.៨. ការលើកទឹកចិត្តគ្រូបង្រៀន

ការផ្តល់រង្វាន់លើកទឹកចិត្ត រាប់តាំងពីការសរសើរផ្ទាល់មាត់ ការផ្តល់ប័ណ្ណសរសើរ ការផ្តល់រង្វាន់ការអនុញ្ញាតឱ្យឈប់សម្រាកជាពិសេស។ល។លោកBLASE (2000) បានលើកឡើងថាការសរសើរពិតជាមានសារៈសំខាន់ណាស់ សម្រាប់គ្រូបង្រៀនពីព្រោះវាជួយលើកទឹកចិត្តបង្កើនការពេញចិត្តចំពោះ ខ្លួនឯងបង្កើនប្រសិទ្ធភាពការងារ និងជំរុញឱ្យគ្រូមានទម្លាប់ក្នុងការឆ្លុះបញ្ចាំងខ្លួនឯង។ការសរសើរ បានចូលរួមក្នុងការពង្រឹងយុទ្ធសាស្ត្របង្រៀន ឱ្យមានប្រសិទ្ធភាពព្រោះវាធ្វើឱ្យគ្រូម្នាក់ៗ ហ៊ានសាកល្បងនូវវិធីសាស្ត្រថ្មី និងមានគំនិតច្នៃប្រឌិតក្នុងការបង្កើតអ្វីដែលប្លែកសម្រាប់ការបង្រៀន។ ការផ្តល់ប័ណ្ណសរសើរឬការផ្តល់រង្វាន់ទោះតិចបានបង្ហាញដល់ពួកគាត់ បានដឹងថាការខិតខំរបស់គាត់កំពុងតែទទួលបានការគាំទ្រពីថ្នាក់ដឹកនាំព្រមទាំងសមាជិករួមអាជីព ហើយការធ្វើបែបនេះក៏ជាសញ្ញាបញ្ជាក់ប្រាប់អ្នកដទៃទៀតថាពួកគាត់ក៏អាចមាន ឱកាសទទួលបានសរសើរ ដែលប្រសិនបើគាត់ ខិតខំបំពេញការងារដោយយកចិត្តទុកដាក់ និងប្រកបដោយវិជ្ជាជីវៈ។

យោងប្រកាសលេខ ៧៦១ អយក.ក្រប ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ ស្តីពីការកំណត់គោលការណ៍លក្ខណៈវិនិច្ឆ័យ និងនីតិវិធីនៃការវាយតម្លៃនាយក នាយិកាសាលារៀនល្អ និងគ្រូបង្រៀនល្អសម្រាប់ពានរង្វាន់ និងថវិការអមពានរង្វាន់លើកទឹកចិត្តក្នុងសន្និបាតអប់រំ។ ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលអប់រំនិងមានគោលដៅផ្តល់ពានរង្វាន់ និងផ្តល់ថវិការអមពានរង្វាន់ដល់ជ័យលាភីនាយកនាយិការសាលារៀនល្អនិងលោកគ្រូបង្រៀនល្អប្រចាំឆ្នាំនីមួយៗ និងលើកទឹកចិត្តបុគ្គលអប់រំដែលមានស្នាដៃជានាយកនាយិកាសាលារៀនល្អនិងលោកគ្រូបង្រៀនល្អ ដើម្បីពង្រឹងការគ្រប់គ្រងការបង្រៀននិងរៀនឱ្យមានគុណភាពនិងប្រសិទ្ធភាព។

## ២.៩. សង្ខេបរំលឹកទ្រឹស្តី

ឆ្លងតាមការសិក្សាលើទ្រឹស្តី គោលនយោបាយ យុទ្ធសាស្ត្រកំណែទម្រង់ ដែលទាក់ទងទៅនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន លក្ខសម្បត្តិគ្រូបង្រៀននៅសតវត្សទី២១ កំណែទម្រង់គ្រូបង្រៀន កំណែទម្រង់អាទិភាពឆ្នាំ២០១៤-២០១៨ កំណែទម្រង់២០១៩-២០២៣ និងចក្ខុវិស័យឆ្នាំ២០៣០ នៅក្នុងផែនការយុទ្ធសាស្ត្រចតុកោណដំណាក់ទី៤ អាណត្តិទី៦ ដែលបានចាត់ទុកធនធានមនុស្សជាអាទិភាពទី១។ លទ្ធផលនៃកាបណ្តុះបណ្តាលគ្រូពន្លឿនទាំង៣ជំនាន់ចំនួន១៦៩១នាក់ ស្រី៥៥២នាក់ ទទួលបានជោគជ័យអ្វីខ្លះ ក្រោយពីបានវិលត្រឡប់ទៅបង្រៀនតាមអង្គភាពដើមតាមរាជធានី ខេត្ត ក្រុង។ កត្តាទាំងអស់នេះដែលជាចម្ងល់ជាច្រើន ដែលធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវចង់ពិនិត្យមើលឃើញថាតើក្រោយទទួលការបណ្តុះបណ្តាលលោកគ្រូពន្លឿនទទួលបានពីការចូលរួមយ៉ាងណា មានការគាំទ្រកម្រិតណា ហេតុទាំងនេះហើយបានសិក្សាស្រាវជ្រាវបានយកប្រធានបទស្តីពី៖ ទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំយកមកសិក្សាដើម្បីឆ្លើយតបទៅនឹងចម្ងល់ និងកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាទទួលបានកម្រិតណា និងដើម្បីឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរបស់ក្រសួង យុវជន និងកីឡាក្នុងបរិបទកំណែទម្រង់ ក៏ដូចជាភាគីពាក់ព័ន្ធផ្សេងៗទៀត។

ដើម្បីឆ្លុះបញ្ចាំងឱ្យបានច្បាស់ប្រធានបទស្តីពី ទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ និង គោលបំណងនៃការស្រាវជ្រាវក្នុងការសិក្សាស្រាវជ្រាវនេះមានគោលបំណងពីរ៖ (ក). រកឱ្យឃើញនូវទស្សនៈរបស់គ្រូនិងគ្រូពន្លឿនក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ។ (ខ). រកឱ្យឃើញពីការប្រៀបធៀបទស្សនៈរបស់គ្រូ និងគ្រូពន្លឿនដោយផ្អែកលើភេទនិងបទពិសោធន៍ការងារ។ សំណួរស្រាវជ្រាវនៃប្រធានបទខាងលើនេះគឺ៖ (ក). តើទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំមានលក្ខណៈដូចម្តេចខ្លះ? (ខ). តើការប្រៀបធៀបទស្សនៈយល់ឃើញរបស់គ្រូ និងគ្រូពន្លឿនដោយផ្អែកលើភេទ បទពិសោធន៍ការងារមានលក្ខណៈដូចម្តេចខ្លះ?

ដើម្បីសម្រេចបាននូវគោលបំណងនៃការស្រាវជ្រាវខាងលើ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសនូវឧបករណ៍ស្រាវជ្រាវ ការជ្រើសរើសភាគសំណាក ការប្រមូលទិន្នន័យ និងវិធីសាស្ត្រស្រាវជ្រាវមួយចំនួនដែលនឹងត្រូវបានលើកយកមកសិក្សានៅជំពូកទី៣។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី ៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ដំណើរការនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានចែកជាពីរដំណាក់កាលសំខាន់ៗ។ ដំណាក់កាលទីមួយគឺជាការ ពិនិត្យមើលឯកសារនានាដែលពាក់ព័ន្ធដែលមានពីមុនស្រាប់។ នៅដំណាក់កាលទីមួយនេះ អ្នកស្រាវ ជ្រាវព្យាយាមសិក្សាស្វែងរកឯកសារផ្សេងៗ ដែលទាក់ទងនឹងប្រធានបទហើយយកវាមកសិក្សាមន្ថែម និងយកវាជាឯកសារយោងផងដែរ។ ដំណាក់កាលទីពីរគឺជាការចុះប្រមូលព័ត៌មាន ដោយបង្កើតកម្រងសំណួរតាម Google form ហើតទម្លាក់តាម telegram និង chat facebook ដើម្បីឱ្យអ្នកពាក់ព័ន្ធចូលរួមឆ្លើយសំណួរពីចម្ងាយ ។ នៅក្នុងដំណាក់កាលនេះ កម្រងសំណួរត្រូវបានរៀបចំឡើងសម្រាប់ជាមូលដ្ឋានក្នុងការប្រមូលព័ត៌មាន ។ ការយកកម្រងសំណួរទៅប្រមូលព័ត៌មានមានគោលបំណងស្វែង រកព័ត៌មានផ្សេងៗពីភាគីពាក់ព័ន្ធគឺចង់បានព័ត៌មានពីពួកគាត់។

## ៣.២ វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវនេះជា ការស្រាវជ្រាវតាមបែបបរិមាណវិស័យ ។ ចំពោះប្រធានបទទស្សនៈយល់ឃើញគ្រូ គ្រូបន្ទៀនក្រោយវគ្គការបណ្តុះបណ្តាល នៅវិទ្យាស្ថានជាតិអប់រំ ៖ ករណីសិក្សាខេត្តស្វាយរៀង គឺអ្នកស្រាវជ្រាវសម្រេច ជ្រើសរើសយក វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យមកធ្វើជាវិធីសាស្ត្រក្នុងការស្រាវជ្រាវ ដោយផ្អែកទៅលើ សំណួរស្រាវជ្រាវនៃប្រធានបទនេះ ។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យឱ្យបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើតកម្រងសំណួរស្រាវជ្រាវពីរប្រភេទ ។ ប្រភេទទី១ គឺសម្រាប់គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលគ្រូពន្លឿនកម្រិតមូលដ្ឋាន ឆ្ពោះទៅរកបរិញ្ញាបត្រ និងប្រភេទទី ២ គឺសម្រាប់គណៈគ្រប់គ្រងសាលា លោកគ្រូអ្នកគ្រូដែលមិនបានចូលរួមវគ្គពន្លឿន ។ ប្រភេទសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ គឺទម្រង់កម្រងសំណួរបំពេញ

សម្រាប់នាយក នាយិកា នាយករង នាយិការង និងលោកគ្រូអ្នកគ្រូ ដើម្បីធ្វើការបំពេញដែលចំណាយពេលប្រមាណពី ២០នាទី ទៅ ៣០នាទី។ ទម្រង់កម្រងសំណួរអ្នកសិក្សាស្រាវជ្រាវបានរៀបចំជា ៥ផ្នែក។ ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួន និងបទពិសោធន៍ការងារមាន ៧សំណួរទាក់ទងទៅនឹងភេទ និងអាយុរបស់អ្នកចូលរួមបំពេញកម្រងសំណួរ។ ផ្នែកទី២៖ រយៈពេលបណ្ដុះណ្ដាលគ្រូពន្លឿន មាន៤សំណួរដែលចង់ដឹងអំពី រយៈពេល នាយក នាយិកា នាយករង នាយិការង គណនេយ្យ ប្រធានក្រុមបច្ចេកទេស ឬគ្រូបង្រៀន ដែលចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល ផ្នែកទី៣៖ ទស្សនៈគ្រូពន្លឿន ចំពោះគ្រូឧទ្ទេស មាន ១៣ សំណួរ ដែលចង់ដឹង ពីការការបង្រៀនរបស់គ្រូឧទ្ទេស ក្នុងវគ្គបណ្ដុះបណ្ដាល ផ្នែកទី៤៖ ទស្សនៈគ្រូពន្លឿន ដែលពួកគាត់ទទួលបានក្រោយវគ្គបណ្ដុះបណ្ដាល មាន១៣សំណួរ ដែលចង់ដឹងពី សមត្ថភាពគ្រូពន្លឿនដែលបានសិក្សាចប់ពីវគ្គបណ្ដុះបណ្ដាល និង ផ្នែកទី៥៖ ទស្សនៈលោគ្រូអ្នកគ្រូ ពន្លឿន ទៅលើលទ្ធផលសិក្សារបស់សិស្ស មាន៦សំណួរ ដែលចង់ដឹងពីឥទ្ធិពលគ្រូពន្លឿនទៅលើការសិក្សារបស់សិស្ស កន្លងទៅទទួលបានលទ្ធផលយ៉ាងដូចម្ដេចខ្លះ? អ្នកចូលរួមអនុវត្តមានការពេញចិត្តកម្រិតណា។

## ៣.៤. ការជ្រើសរើសគំរូសំណាក

ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីជ្រើសរើសសំណាក ឱ្យឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ ដោយកំណត់យកតែសំណាកណាដែលទាក់ទងទៅនឹងសំណួរស្រាវជ្រាវដែលមានប្រយោជន៍ ដើម្បីទទួលបានទិន្នផលចាំបាច់ និងជាក់លាក់ជាពិសេសអាចឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវប្រធានបទខាងលើ។ ខ្ញុំបានជ្រើសរើសសំណាក ចេញពីវិទ្យាល័យ៧ ដែលអ្នកសិក្សាលើកយកមកស្រាវជ្រាវគឺ៖ នាយក នាយិកាសាលា ៧នាក់ នាយករង នាយិការង ១០នាក់ និងលោកគ្រូអ្នកគ្រូ រួមទាំងបុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន(គណនេយ្យ លេខា បណ្ណារក្ស) ៨៧នាក់ សរុបទាំងអស់ ១០៤នាក់ ត្រូវបានជ្រើសរើសដោយចៃដន្យមកពីសាលាគោលដៅទាំង ៧ ក្នុងខេត្តស្វាយរៀង ដើម្បីឱ្យពួកគាត់បំពេញនូវកម្រងសំណួរនិក្ខេបបទស្ដីពី "**ទស្សនៈយល់របស់ឃើញគ្រូ**

**និងគ្រូពន្លឿនក្រោយវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ"**។ សំណាកទាំងអស់គឺជ្រើសរើស គណៈគ្រប់គ្រងសាលា និងលោកគ្រូអ្នកគ្រូចេញពីវិទ្យាល័យ៧ ក្នុង ក្រុង/ស្រុកទាំង ៧ ក្នុងខេត្តស្វាយរៀងដែលខេត្តស្វាយរៀងមានវិទ្យាល័យទាំងអស់ចំនួន២០(ប្រជាករ) ក្នុងនោះរួមមាន **ទី១៖ ក្រុងស្វាយរៀង** វិទ្យាល័យ១ (បុគ្គលិកសរុប ៦៥នាក់) **ទី២៖ ក្រុងបាវិត** វិទ្យាល័យ១(បុគ្គលិកសរុប ៥៤នាក់) **ទី៣៖ ស្រុករំដួល** វិទ្យាល័យ១ (បុគ្គលិកសរុប ៥៨នាក់) **ទី៤៖ ស្រុករមាសហែក** វិទ្យាល័យ១ (បុគ្គលិកសរុប ៤១នាក់) **ទី៥៖ ស្រុកស្វាយជ្រុំ** វិទ្យាល័យ១(បុគ្គលិកសរុប ៦៨នាក់) **ទី៦៖ ស្រុកស្វាយទាប** វិទ្យាល័យ១ (បុគ្គលិកសរុប ៤៣នាក់) **ទី៧៖ ស្រុកចន្ទ្រា** វិទ្យាល័យ១(បុគ្គលិកសរុប ៣៦នាក់) សរុបរួមទាំង ៧វិទ្យាល័យមានបុគ្គលិកចំនួន ៣៦៥នាក់ (មន្ទីរអេយកខេត្តស្វាយរៀង ស្ថិតិបុគ្គលិកអប់រំ ឆ្នាំ២០២០)។ កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា និងលោកគ្រូអ្នកគ្រូគឺផ្តោតលើចំណុចសំខាន់ ៥គឺ ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួន និងបទពិសោធន៍ការងារ ផ្នែកទី២៖ ៖ រយៈពេលបណ្តុះណ្តាលគ្រូពន្លឿន ផ្នែកទី៣៖ ទស្សនៈគ្រូពន្លឿន ចំពោះគ្រូឧទ្ទេស ផ្នែកទី៤៖ ទស្សនៈគ្រូពន្លឿន ដែលពួកគាត់ទទួលបានក្រោយវគ្គបណ្តុះបណ្តាល ផ្នែកទី៥៖ ទស្សនៈលោគ្រូ អ្នកគ្រូ ពន្លឿន ទៅលើលទ្ធផលសិក្សារបស់សិស្ស ។ ការជ្រើសរើសមុខសញ្ញានៃភាគសំណាកទាំងអស់មកធ្វើការសិក្សាស្រាវជ្រាវនេះ គឺដើម្បីផ្ទៀងផ្ទាត់គ្នាថាតើចម្លើយដែលបានមកពីភាគសំណាកទាំងអស់នោះមានភាពសុក្រឹត ឬមិនសុក្រឹត។

ការជ្រើសរើសសំណាកនៅតាម ក្រុង/ស្រុក មិនដូចគ្នានោះទេ គឺវាអាស្រ័យលើចំនួនបុគ្គលិកនៅតាមវិទ្យាល័យនីមួយៗ ហើយចំនួនសំណាក ដែលចូលរួមឆ្លើយ គឺធ្វើឡើងតាមរយៈ Google form។ តារាងទី១ ចំនួនវិទ្យាល័យ ចំនួនបុគ្គលិកអប់រំ និងចំនួនសំណាកដែលបានជ្រើសរើសតាមស្រុកនីមួយៗ

**តារាង ៣.១ ចំនួនសំណាកអ្នកចូលរួម**

| ល.រ | ឈ្មោះក្រុង/ស្រុក | ចំនួន វិ.ល័យ | ចំនួនគ្រូ | ភាគរយ | ចំនួន សំណាក | ភាគរយ |
|---|---|---|---|---|---|---|
| ១ | ស្រុក ចន្ទ្រ | ១ | ៣៦ | ៩.៨៦% | ១០ | ៩.៨៦% |
| ២ | ស្រុក រំដួល | ១ | ៥៨ | ១៥.៨៩% | ១៧ | ១៥.៨៩% |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | ស្រុក រមាសហែក | ១ | ៤១ | ១១.២៣% | ១២ | ១១.២៣% |
| ៤ | ស្រុក ស្វាយជ្រុំ | ១ | ៦៨ | ១៨.៦៣% | ១៩ | ១៨.៦៣% |
| ៥ | ក្រុង ស្វាយរៀង | ១ | ៦៥ | ១៧.៨១% | ១៩ | ១៧.៨១% |
| ៦ | ស្រុក ស្វាយទាប | ១ | ៤៣ | ១១.៧៨% | ១២ | ១១.៧៨% |
| ៧ | ក្រុង បាវិត | ១ | ៥៤ | ១៤.៧៩% | ១៥ | ១៤.៧៩% |
| សរុប | | ៧ | ៣៦៥ | ១00% | ១0៤ | ១00% |

## ៣.៥. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបានតាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធី SPSS ដើម្បីវិភាគតាមបែបបរិមាណវិស័យ និងកម្មវិធី Microsoft excel សម្រាប់សង់ក្រាប និងបកប្រែ ភាគសំណាកនីមួយៗជាភាសាខ្មែរ។ ចំពោះការវិភាគនេះអ្នកសិក្សាស្រាវជ្រាវបានវិភាគលើចំណុចសំខាន់មួយចំនួនដូចជា៖ រយៈពេលបណ្តុះណ្តាលគ្រូពន្លឿន ទស្សនៈគ្រូពន្លឿនចំពោះគ្រូឧទ្ទេស ទស្សនៈគ្រូលើគ្រូពន្លឿនដែលពួកគាត់ទទួលបានក្រោយវគ្គបណ្តុះបណ្តាល និង ទស្សនៈលោកគ្រូអ្នកគ្រូពន្លឿនទៅលើលទ្ធផលសិក្សារបស់សិស្ស ។

រាល់ទិន្នន័យទាំងអស់ដែលបានធ្វើការវិភាគរួច និងត្រូវបានទាញចេញមកបង្ហាញទៅតាមគោលបំណងសំខាន់ៗទាំងពីរនៃការសិក្សាស្រាវជ្រាវគឺ ដើម្បីងាយស្រួលក្នុងការបង្ហាញ និងធ្វើសេចក្តីសន្និដ្ឋានពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ។ បន្ទាប់ពីទទួលបានលទ្ធផលហើយយើងនឹងទាញសេចក្តីសន្និដ្ឋានព្រមទាំងធ្វើការផ្ទៀងផ្ទាត់ជាមួយចំណោទបញ្ហា ដែលបានលើកឡើងជាសំណួរស្រាវជ្រាវ និងគោលបំណងនៃការសិក្សាស្រាវជ្រាវនេះ ហើយធ្វើការវាយតម្លៃទៅលើស្ថានភាពកំណែទម្រង់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន តាមរយៈវគ្គបណ្តុះបណ្តាល គ្រូពន្លឿនគ្រូបង្រៀនកម្រិតមូលដ្ឋានឆ្ពោះទៅរកគ្រូបង្រៀនកម្រិតឧត្តម។ ជាចុងក្រោយ អ្នកស្រាវជ្រាវក៏បានលើកជាអនុសាសន៍ និងសំណូមពរចំពោះក្រសួងអប់រំ យុវជន

និងកីឡា ទៅលើ វគ្គបណ្តុះបណ្តាលគ្រូពន្លឿននេះ។

## ៣.៦ របៀបនៃការបង្ហាញព័ត៌មាន

- Mean ជាមធ្យមក្នុងការវាយតម្លៃទៅលើស្ថានភាពនៃវគ្គបណ្តុះបណ្តាលគ្រូពន្លឿនកម្រិតមូលដ្ឋាន ឆ្ពោះទៅរកគ្រូបង្រៀនកម្រិតឧត្តម ដែល Mean ស្ថិតនៅចន្លោះ៖

+ Mean = ៣.៥០ ឡើងទៅ មានកម្រិតខ្ពស់

+ Mean = ២.៥០ ដល់ ៣.៣៩ មានកម្រិតមធ្យម

+ Mean < ២.៥០ កម្រិតទាប (យោងតាមលោក Oxford and Burry-stock 1995)

- SD ជាគម្លាតស្តង់ដា
- n ជាទំហំនៃ គម្រូសំណាកក្នុងការស្រាវជ្រាវ
- t ជាតម្លៃស្ថិតិនៃការវិភាគតេស្ត Independent Sample t-Test
- F ជាតម្លៃស្ថិតិនៃការវិភាគតេស្ត ANOVA
- SS ជាតម្លៃ នៃផលបូកការេ (sum of square)
- Ms ជាតម្លៃមធ្យម ការេ (Mean square)
- df ជាចំនួនដឺក្រេសេរី ឬអថេរសេរី
- p ជាកម្រិតនៃភាពជឿជាក់ដែលមានទំហំ ០.០៥

# ជំពូកទី៤

# លទ្ធផល

# ជំពូកទី៤ ៖ លទ្ធផល

ជំពូកទី៤នេះនឹងបង្ហាញពីលទ្ធផល នៃការវិភាគទិន្នន័យលើប្រធានបទ ៖ទស្សនៈយល់ឃើញគ្រូ និងគ្រូពន្លឿនក្រោយការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ ៖ ទស្សនៈរបស់ គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និង លោកគ្រូ អ្នកគ្រូដែលបានចូលរួមវគ្គបណ្តុះបណ្តាលក្នុងកម្មវិធី ពន្លឿន ក្នុងខេត្តស្វាយរៀង។ លទ្ធផលនៃការវិភាគទិន្នន័យត្រូវបានយកមកបកស្រាយ តាមរបៀបដូចខាងក្រោម៖

## ៤.១. មុខងារបច្ចុប្បន្ន និងបទពិសោធន៍ការងារ

### ៤.១.១. តួនាទី

ផ្នែកនេះយើងធ្វើការស្រាវជ្រាវ ដោយបែងចែក ចំនួនតាមតួនាទីរបស់អ្នកចូលរួមឆ្លើយកម្រងសំណួរទាំងអស់រួមមាន ៖ គណៈគ្រប់គ្រងសាលា គណនេយ្យ លេខាធិការ លោកគ្រូអ្នកគ្រូ ដែលបានចូលរួម និងមិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលក្នុងកម្មវិធីពន្លឿន ឆ្ពោះទៅរកគ្រូបង្រៀនកម្រិតឧត្តម។

រូបភាពទី ៤.១. តួនាទីរបស់អ្នកចូលរួមបំពេញកម្រងសំណួរ




យោងតាមតារាង ៤.១ ខាងលើ បញ្ជាក់ថាក្នុងចំណោមអ្នកចូលបំពេញកម្រងសំណួរ ទាំងអស់

ដែលជ្រើសរើសចេញពី វិទ្យាល័យទាំង ៧ ក្នុងក្រុង/ស្រុកទាំង៧ ក្នុងខេត្តស្វាយរៀង មានតួនាទីដូចខាងក្រោម ៖ តួនាទីនាយកមាន ១១នាក់ ស្មើនឹង ១០.៥៨ % គណនេយ្យសាលាមាន ២នាក់ ស្មើនឹង ១.៩២% លេខាធិការមាន ៤នាក់ ស្មើនឹង ៣.៨៥% គ្រូបង្រៀនមាន ៨៧នាក់ ស្មើនឹង ៨៣.៦៥%។

### ៤.១.២. បទពិសោធន៍

បន្ទាប់ពីធ្វើការវិភាគលើការផ្នែកតួនាទីនៅចំណុច ៤.១.១ ខាងលើយើងឃើញថាក្រុមគោលដៅដែលចូលរួមបំពេញកម្រងសំណួរមានគ្រប់ភាគីពាក់ព័ន្ធនៅសាលារៀន រួមទាំងនាយកសាលា រហូតដល់បុគ្គលិកបង្រៀន។ ចំពោះផ្នែកនេះយើងនឹងធ្វើការវិភាគទៅលើបទពិសោធន៍បំពេញការងារទៅតាមតួនាទីរបស់អ្នកចូលរួមបំពេញកម្រងសំណួរ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ពីទស្សនៈយល់ឃើញរបស់ គ្រូបង្រៀនតាមរយៈវគ្គបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ឆ្ពោះទៅរកគ្រូបង្រៀនកម្រិតឧត្តម ដែលនឹងបម្រើការងារនៅតាមវិទ្យាល័យនានា ក្នុងខេត្តស្វាយរៀង។ យោងតាមរូបភាពទី ៤.២. ខាងក្រោមនេះបង្ហាញថា បទពិសោធន៍ការងារចន្លោះពី ១ ទៅ ៥ឆ្នាំមាន ១៦នាក់ ស្មើនឹង ១៥.៣៨% ចន្លោះ ៦ ទៅ ១០ឆ្នាំមាន ៣១នាក់ ស្មើនឹង ២៩.៨១% ចន្លោះ ១១ទៅ១៥ឆ្នាំមាន ១៣នាក់ ស្មើនឹង ១២.៥០% និងបទពិសោធន៍ការងារចាប់ពី១៦ឆ្នាំឡើងទៅ មាន ៤៤នាក់ ស្មើនឹង ៤២.៣១%។

រូបភាពទី ៤.២. បទពិសោធន៍បំពេញការងារ



សរុបមកចំពោះបទពិសោធន៍បំពេញការងាររបស់ក្រុមគោលដៅឃើញថា គ្រូបង្រៀនដែលមានបទពិសោធន៍ ១៦ឆ្នាំឡើងទៅមានចំនួនច្រើនលើសលុប គឺមាន ៤៤នាក់ ស្មើនឹង ៤២.៣១%។ ចំណែកបទពិសោធន៍ចន្លោះ ៦ទៅ ១០ឆ្នាំ មាន ៣១នាក់ ស្មើនឹង ២៩.៨១% ច្រើនជាងបន្ទាប់ក្រុមគ្រូបង្រៀនចន្លោះបទពិសោធន៍ ១៦ឆ្នាំ។ បទពិសោធន៍ការងារចន្លោះ ១ ទៅ ៥ឆ្នាំ មានចំនួនប្រហាក់ប្រហែលទៅនឹង ចន្លោះ ១១ ទៅ ១៥ឆ្នាំ។ តែទោះជាយ៉ាងណា គ្រូបង្រៀនភាគច្រើននៅតាមវិទ្យាល័យសុទ្ធតែមានបទពិសោធន៍ការងារយូរឆ្នាំ ក្នុងការបង្រៀនសិស្ស ដែលពិតជាអាចយល់ដឹងបានច្រើនពីកម្មវិធីតាមប្រព័ន្ធពន្លឿននេះ។

### ៤.១.៣. កម្រិតវប្បធ៌មគ្រូបង្រៀន

បន្ទាប់ពីធ្វើការវិភាគលើការផ្នែកតួនាទីនៅចំណុច ៤.១.២. ខាងលើយើងឃើញថាក្រុមគោលដៅដែលចូលរួមបំពេញកម្រងសំណួរមានគ្រប់ភាគីពាក់ព័ន្ធនៅសាលារៀន រួមទាំងនាយកសាលា រហូតដល់បុគ្គលិកបង្រៀន។ ចំពោះផ្នែកនេះយើងនឹងធ្វើការវិភាគទៅលើកម្រិតវប្បធម៌ របស់ លោគ្រូ អ្នកគ្រូដែលបានចូលរួមបំពេញកម្រងសំណួរ។ កម្រិតវប្បធ៌មរបស់អ្នកចូលរួមមានសារៈសំខាន់ណាស់សម្រាប់កិច្ចការស្រាវជ្រាវនេះ ក្នុងការធានាប្រាកដថា អ្វីដែលពួកគាត់បានឆ្លងកាត់ និង យល់ឃើញវាអាចឆ្លុះបញ្ចាំងពីតថភាពជាក់ស្តែងបាន។

យោងតាមតារាង ៤.៣. ខាងក្រោមបញ្ជាក់ថាក្នុងចំណោម អ្នកចូលរួមបំពេញកម្រងសំណួរទាំងអស់ដែលបានជ្រើសរើសចេញពី វិទ្យាល័យទាំង ៧ ក្នុងក្រុង/ស្រុកទាំង ៧ ក្នុងខេត្តស្វាយរៀងបញ្ជាក់ថាគ្រូបង្រៀនដែលមាន សញ្ញាបត្របាក់ឌុបមាន ៧នាក់ ស្មើនឹង ៦.៧៣% សញ្ញាបត្របរិញ្ញាបត្រមាន៨២ នាក់ ស្មើនឹង ៧៨.៨៥% សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មាន ១៥នាក់ ស្មើនឹង ១៤.៤២%។

សរុបមកគ្រូបង្រៀនដែលកំពុងបង្រៀននៅតាមវិទ្យាល័យនានា មានកម្រិតសញ្ញាបត្របរិញ្ញាបត្រខ្ពស់ជាងគេ គឺ ៨២ នាក់ ស្មើនឹង ៧៨.៨៥% ខណៈដែលគ្រូបង្រៀនដែលមានសញ្ញាបត្របាក់ឌុបមានត្រឹមតែ ៧នាក់ប៉ុណ្ណោះ។ ទាំងនេះអាចសបញ្ជាក់ឱ្យដឹងថា គ្រូភាគច្រើនស្របតាមគុណវុឌ្ឍិគ្រូបង្រៀនដែលជាផលជៈនៃកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលស្ថិតនៅក្នុងសសរស្តម្ភទី១ក្នុង

ចំណោមសរសេរសស្តម្ភទាំង៥ គឺកំណែទម្រង់គុណវុឌ្ឍិគ្រូបង្រៀន។

រូបភាពទី ៤.៣. កម្រិតវប្បធ៌មគ្រូបង្រៀន




### ៤.១.៤. ចំនួនអ្នកចូលរួមវគ្គពង្រឹង

បន្ទាប់ពីធ្វើការវិភាគលើផ្នែកកម្រិតវប្បធ៌មនៅចំណុច ៤.១.៣. ខាងលើយើងឃើញថាក្រុមគោលដៅដែលចូលរួមបំពេញកម្រងសំណួរមានគ្រប់ភាគីពាក់ព័ន្ធនៅសាលារៀន រួមទាំងនាយកសាលារហូតដល់បុគ្គលិកបង្រៀន។ ចំពោះផ្នែកនេះយើងនឹងធ្វើការវិភាគទៅលើចំនួនអ្នកចូលរួម និងមិនបានចូលរួមក្នុងវគ្គពង្រឹង របស់ លោកគ្រូ អ្នកគ្រូដែលបានចូលរួមបំពេញកម្រងសំណួរ។ចំពោះអ្នកចូលរួមក្នុងវគ្គពង្រឹងមានសារៈសំខាន់ណាស់ព្រោះពួកគាត់ជាអ្នកឆ្លងកាត់ផ្ទាល់ ដូចនេះពួកគាត់យល់បានច្បាស់។

យោងតាមរូបភាព ៤.៤. ខាងក្រោមបញ្ជាក់ថាក្នុងចំណោម អ្នកចូលរួមបំពេញកម្រងសំណួរទាំងអស់ដែលបានជ្រើសរើសចេញពី វិទ្យាល័យទាំង ៧ ក្នុងក្រុង/ស្រុកទាំង ៧ ក្នុងខេត្តស្វាយរៀងបញ្ជាក់ថាគ្រូបង្រៀនដែលបានចូលរួមវគ្គពង្រឹងគ្រូបង្រៀនកម្រិតមូលដ្ឋាន ឆ្ពោះទៅរកគ្រូបង្រៀនកម្រិតឧត្តមដែលត្រូវបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំមាន ៥៥នាក់ ស្មើនឹង ៥២.៨៨% នឹងគ្រូមិនបានចូលរួមក្នុងវគ្គពង្រឹងនេះ ហើយបានចូលរួមបំពេញកម្រងសំណួរនេះមាន ៤៩នាក់ ស្មើនឹង ៤៧.១២%។

សរុបមក គ្រូបង្រៀន ដែលបានឆ្លងកាត់វគ្គពង្រឹង ហើយចូលរួមបំពេញកម្រងសំណួរមាន

ចំនួនច្រើនជាងគេ គឺ ៥៥នាក់ ស្មើនឹង ៥២.៨៨%។

រូបភាពទី ៤.៤. ចំនួនគ្រូបាន និងមិនបានចូលរួមវគ្គពន្លឿន




### ៤.១.៥ ចំនួនអ្នកចូលរួមវគ្គពន្លឿនតាមមុខវិជ្ជាឯកទេស

រូបភាពទី ៤.៥. ចំនួនគ្រូបានចូលរួមវគ្គពន្លឿនតាមមុខវិជ្ជាឯកទេស



បន្ទាប់ពីធ្វើការវិភាគលើផ្នែកចំនួនអ្នកចូលរួម និងអ្នកមិនបានចូលរួម វគ្គពន្លឿនហើយ នៅចំណុច ៤.១.៤. ខាងលើ យើងឃើញថាក្រុមគោលដៅដែលចូលរួមបំពេញកម្រងសំណួរមានគ្រប់ភាគីពាក់ព័ន្ធនៅសាលារៀន រួមទាំងនាយកសាលា រហូតដល់បុគ្គលិកបង្រៀន។ ចំពោះផ្នែកនេះយើងនឹងធ្វើការវិភាគទៅលើចំនួន លោកគ្រូបង្រៀន ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូពន្លឿនកម្រិតមូលដ្ឋានឆ្ពោះទៅរកគ្រូបង្រៀនកម្រិតឧត្តម នៅវិទ្យាស្ថានជាតិអប់រំ។

យោងតាមដ្យាក្រាប ខាងលើបញ្ជាក់ថាក្នុងចំណោម អ្នកចូលរួមបំពេញកម្រងសំណួរទាំងអស់ដែលបានជ្រើសរើសចេញពី វិទ្យាល័យទាំង ៧ ក្នុងក្រុង/ស្រុកទាំង ៧ ក្នុងខេត្តស្វាយរៀងបញ្ជាក់ថាគ្រូបង្រៀនដែលបានចូលរួមវគ្គពន្លឿនគ្រូបង្រៀនកម្រិតមូលដ្ឋាន ឆ្ពោះទៅរកគ្រូបង្រៀនកម្រិតតាមមុខវិជ្ជាឯកទេសមាន គ្រូសីលធម៌មាន ៤នាក់ ស្មើនឹង ៧.២៧% គ្រូប្រវត្តិវិទ្យាមាន ៤នាក់ ស្មើនឹង ៧.២៧% គ្រូភូមិវិទ្យាមាន ១នាក់ ស្មើនឹង ០.៩៦% គ្រូផែនដីវិទ្យាមាន ៣នាក់ ស្មើនឹង ៥.៤៥% គ្រូជីវៈវិទ្យាមាន ៧នាក់ ស្មើនឹង ១២.៧៣% គ្រូរូបវិទ្យាមាន ៤នាក់ ស្មើនឹង ៧.២៧% គ្រូគីមីវិទ្យាមាន ៧នាក់ ស្មើនឹង ១២.៧៣% គ្រូគណិតវិទ្យាមាន ១៥នាក់ ស្មើនឹង ២៧.២៧% និងគ្រូភាសាខ្មែរ មាន១០នាក់ ស្មើនឹង ១៨.១៨%។

សរុបមកគ្រូឯកទេសគណិតវិទ្យាបានចូលរួមបំពេញកម្រងសំណួរច្រើនជាងគេ គឺមាន ១៥នាក់ ស្មើនឹង ២៧% គ្រូឯកទេសជីវវិទ្យា និងឯកទេសគីមីវិទ្យាមានចំនួនដូចគ្នា ដែលបានចូលរួមឆ្លើយសំណួរ ៧នាក់ ស្មើនឹង ១២.៧៣% គ្រូឯកទេសសីលធម៌ និងគ្រូឯកទេសប្រវត្តិវិទ្យាមានចំនួនដូចគ្នាដែល គឺមាន ៤នាក់ ស្មើនឹង ៧.២៧% មានតែគ្រូឯកទេសភូមិវិទ្យាទេដែលចូលរួមឆ្លើយសំណួរបានតិចជាងគេ គឺមានតែ ១នាក់ ស្មើនឹង ០.៩៦%។

## ៤.២. ការយល់ឃើញលើវគ្គបណ្តុះបណ្តាល

### ៤.២.១ កម្រិតនៃការពេញចិត្ត លើរយៈពេលនៃការបណ្តុះបណ្តាល

បន្ទាប់ពីធ្វើការវិភាគលើ ចំនួនគ្រូបានចូលរួមវគ្គពន្លឿនតាមមុខវិជ្ជាឯកទេសនៅចំណុច ៤.១.៥ ខាងលើ យើងឃើញថាក្រុមគោលដៅដែលចូលរួមបំពេញកម្រងសំណួរមានគ្រប់ភាគីពាក់ព័ន្ធនៅតាម

សាលារៀន។ ចំពោះផ្នែកនេះយើងនឹងធ្វើការវិភាគទៅកម្រិតនៃការពេញចិត្តរបស់គ្រូពន្លឿន ទៅលើរយៈពេលនៃការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមបង្រៀនតាមវិទ្យាល័យ។

## រូបភាពទី ៤.៦. ចំនួនគ្រូបានចូលរួមវគ្គពន្លឿនតាមមុខវិជ្ជាឯកទេស




យោងតាមក្រាប សរុបមកមានគ្រូដែលពេញចិត្តខ្លាំងមានចំនួនច្រើនជាងគេ គឺមានរហូត ដល់ ៤៩.០៩% និងកម្រិតនៃមិនពេញចិត្តមានចំនួនតិចបំផុតគឺ ៣.៦៤% ដូចនេះរយៈពេលនៃការបណ្តុះបណ្តាលមិនបានប៉ះពាល់ដល់ សតិអារម្មណ៍របស់ លោកគ្រូ អ្នកគ្រូ តាមវិទ្យាល័យទេ។

មានហេតុផលខ្លះៗ ដែលអ្នកចូលរួមបំពេញកម្រងសំណួរឆ្លើយ ពីមូលហេតុនៃកម្រិតពេញចិត្ត។ ក្នុងចំណោម លោកគ្រូ អ្នកគ្រូ ចូលរួមកម្មវិធីពន្លឿន ៥៥នាក់ បានឆ្លើយពីកម្រិតពេញចិត្តបង្គួរមាន ៤៥នាក់ បានប្រាប់ពីមូលហេតុដែលពួកគាត់ពេញចិត្ត។

យោងតាមដ្យាក្រាប ៤.៧. គុណភាពសិក្សារបស់សិស្សវាអាស្រ័យ ៤កត្តា។ កត្តាទី១ គឺអាស្រ័យលើ គុណភាពនៃវិធីសាស្រ្តបង្រៀន មានអ្នកឆ្លើយ ១០នាក់ កត្តាទី២ សមត្ថភាពរបស់អ្នកសិក្សាមានអ្នកឆ្លើយ ១២នាក់ កត្តាទី៣ ឆន្ទៈរបស់អ្នកសិក្សាមានអ្នកឆ្លើយ ៦នាក់ និងកត្តាទី៤ ការខិតប្រឹងប្រែង

របស់អ្នសិក្សាមានអ្នកឆ្លើយរហូតដល់ ១៧នាក់។

**រូបភាពទី ៤.៧. គុណភាពសិក្សារបស់សិស្សរាំអាស្រ័យលើកត្តាផ្សេងៗថែមទៀត**




សរុបមក ការខិតខំប្រឹងប្រែងរបស់អ្នកសិក្សាមានអ្នកឆ្លើយលើសគេ គឺ ១៧នាក់ និង ឆន្ទះរបស់អ្នកសិក្សាមានចំនួនតិចជាងគេមាន ៧នាក់។ ដូចនេះអ្នកសិក្សាស្រាវជ្រាវអាចបញ្ជាក់បានថា ក្រសួងបានធ្វើកំណែទម្រង់ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ឱ្យចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះត្រូវឆ្លង កាត់ការប្រកួត ប្រជែង ការប្រឡងជ្រើសរើស គ្រូដែលមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ ដើម្បី ឱ្យពួកគាត់ទទួលបាននូវចំណេះដឹងគ្រប់គ្រាន់ក្នុងវគ្គបណ្តុះបណ្តាលនេះ ទោះបីរយៈពេលនៃការបណ្តុះ ណ្តាល មានភាពខុសគ្នាទៅ នឹងរយៈពេលការបណ្តុះបណ្តាល គ្រូបរិញ្ញាបត្រ + ១ យ៉ាងណាក៏ដោយ គឺ ត្រូវធ្វើយ៉ាងណាធានាគុណភាព របស់អ្នកសិក្សា។

ចំពោះកម្រិតនៃការពេញចិត្តមធ្យម និងមិនពេញចិត្ត នៃរយៈពេលបណ្តុះបណ្តាលគ្រូកម្រិតមូល ដ្ឋានឆ្ពោះទៅរកគ្រូបង្រៀនកម្រិតឧត្តម។ ក្នុងចំណោម លោកគ្រូ អ្នកគ្រូ ចូលរួមកម្មវិធីពន្លឿន ៥៥ នាក់ បានឆ្លើយពីកម្រិតពេញចិត្តមធ្យម និងមិនពេញចិត្តមាន ១០នាក់ បានប្រាប់ពីមូលហេតុនូវការ

យល់ឃើញរបស់ពួកគាត់។

រូបភាពទី ៤.៨. រយៈពេលអាចប៉ះពាល់ដល់ការសិក្សារបស់សិស្ស




យោងតាមរូបភាព ៤.៨. រយៈពេលអាចប៉ះពាល់ដល់ការសិក្សារបស់សិស្ស។ មូលហេតុទាំងនោះត្រូវបានឆ្លើយដោយអ្នកចូលរួមបំពេញកម្រងសំណួរ គឺសមត្ថភាពរបស់សិស្ស មានកម្រិតមានអ្នកឆ្លើយ ៣នាក់ កត្តាអាយុមាន ៦នាក់ និងការគ្រប់គ្រងពេលវេលាមាន ១នាក់។

សរុបជារួមមក លោកនាយ លោកគ្រូ អ្នកគ្រូដែលបានចូលរួមបំពេញកម្រងភាគតិចបំផុតដែលមិនពេញចិត្តក្នុងវគ្គបណ្តុះបណ្តាលនេះ តែមានមួយភាគធំគឺពេញចិត្ត។ ដូចនេះ លោកគ្រូ អ្នកគ្រូដែលជាសិក្ខាកាម មានភាពទុកចិត្តលើកម្មវិធី ដែលអាចពួកគាត់ ស្វែងយល់ពីចំណេះដឹងបន្ថែម។

### ៤.២.២ ទស្សនៈយល់ឃើញគ្រូពន្លឿន ចំពោះគ្រូឧទ្ទេស

តារាងទី ៤.១. ៖ បង្ហាញពីតម្លៃមធ្យម គំលាតស្តង់ដា អត្ថន័យ លំដាប់ ទស្សនៈរបស់គ្រូ ទៅលើគុណភាពសាស្ត្រាចារ្យ ដែលជាគ្រូឧទ្ទេស គ្រូពន្លឿន

| ល.រ | ចំណេះដឹងតាមខាងផ្នែក | គ្រូបង្រៀន n=៥៥ | អត្ថន័យ | លំដាប់ |
|---|---|---|---|---|

| | | Mean | SD | | |
|---|---|---|---|---|---|
| ១ | អភិវឌ្ឍកម្មវិធីសិក្សា | ៣.១៨ | ០.៩២ | យល់ដឹងបង្គួរ | ១២ |
| ២ | កំណត់បាននូវមេរៀនដែលសមស្របតាមសមត្ថភាពរបស់សិស្ស | ៣.៤៤ | ០.៨១ | យល់ដឹងបង្គួរ | ៨ |
| ៣ | យល់ដឹងពីរបៀបទំនាក់ទំនងជាមួយសិស្ស មាតាបិតាសិស្ស និងសហគមន៍ ប្រកបដោយប្រសិទ្ធភាព | ៣.៣៣ | ០.៧៧ | យល់ដឹងបង្គួរ | ១១ |
| ៤ | បំផុសសំណួរឱ្យសិស្សមានការគិតត្រិះរិះពិចារណា | ៣.៥៦ | ០.៧៤ | យល់ដឹងខ្លាំង | ៤ |
| ៥ | ប្រើប្រាស់សម្ភារឧបទេសបង្រៀន និងរៀនបានសមស្រប | ៣.៤៥ | ០.៨៦ | យល់ដឹងបង្គួរ | ៧ |
| ៦ | បង្កើតគោលដៅសិក្សារបស់សិស្សសមស្រប | ៣.៤៤ | ០.៧៤ | យល់ដឹងបង្គួរ | ៨ |
| ៧ | បង្កើតសកម្មភាពរៀនរបស់សិស្សសំបូរបែប | ៣.១៦ | ០.៨៨ | យល់ដឹងបង្គួរ | ១៣ |
| ៨ | ផ្តល់ព័ត៌មានត្រឡប់ដ៏មានអត្ថប្រយោជន៍ដល់ការសិក្សារបស់សិស្ស | ៣.៤០ | ០.៧៤ | យល់ដឹងបង្គួរ | ១០ |
| | លើកទឹកចិត្តសិស្សឱ្យប្រើប្រាស់បំណិនការគិតត្រិះរិះពិចារណា | ៣.៤៩ | ០.៧៤ | យល់ដឹងបង្គួរ | ៦ |
| ១០ | ចំណេះដឹងឯកទេស | ៣.៥៦ | ០.៨៣ | យល់ដឹងខ្លាំង | ៤ |
| ១១ | ការប្រើប្រាស់វិធីសាស្ត្រលើកទឹកចិត្តសិស្សប្រកបដោយប្រសិទ្ធភាព | ៣.៦៤ | ០.៧៣ | យល់ដឹងខ្លាំង | ៣ |

| | | | | | |
|---|---|---|---|---|---|
| ១២ | ការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព | ៣.៧៧ | 0.៤៥ | យល់ដឹងខ្លាំង | ១ |
| ១៣ | ការតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប្រចាំ | ៣.៦៩ | 0.៤៧ | យល់ដឹងខ្លាំង | ២ |
| | សរុប | ៣.៥១ | 0.៦១ | យល់ដឹងខ្លាំង | |

តាមរយៈទិន្នន័យខាងលើ បានបង្ហាញឱ្យឃើញថា សាស្ត្រាចារ្យដែលជា គ្រូឧទ្ទេសក្នុងកម្មវិធីពន្លឿន នៅវិទ្យាស្ថានជាតិអប់រំ មានការគ្រប់គ្រងថ្នាក់រៀន បានកម្រិតខ្ពស់(Mean=៣.៧៧) និង (SD=0.៤៥)ដោយសារតែសាស្ត្រាចារ្យទាំងអស់យកចិត្តទុកដាក់នឹងការងារ មកបំពេញការងារជាប្រចាំ និងទៀងទាត់ពេលវេលា គ្រូទាំងអស់ភាគច្រើនសុទ្ធតែមានគុណវុឌ្ឍិខ្ពស់ មានទាំងសញ្ញាបត្រ មានទាំងគុណភាព។ ហើយតាមរយៈទិន្នន័យតារាងទីមួយនេះផងដែរបានបង្ហាញឱ្យឃើញថា ចំណេះដឹងវិជ្ជាជីវៈរបស់សាស្ត្រាចារ្យ សុទ្ធតែមានសមត្ថភាពបានកម្រិតខ្ពស់គ្រប់ចំណុចគឺតម្លៃមធ្យមសុទ្ធតែខ្ពស់(Mean > ៣.៥0) ការប្រតិបត្តិវិជ្ជាជីវៈរបស់សាស្ត្រាចារ្យ ដូចជា បំផុសសំណួរឱ្យសិស្សមានការគិតត្រិះរិះពិចារណា ការប្រើប្រាស់វិធីសាស្ត្រលើកទឹកចិត្តសិស្សប្រកបដោយប្រសិទ្ធភាព ការតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាប្រចាំ ប្រើប្រាស់សម្ភារឧបទេសបង្រៀន និងរៀនបានសមស្រប សុទ្ធតែមានមធ្យមភាគខ្ពស់ (Mean >៣. ៥0) លើកលែងតែចំណុចមួយចំនួនតូចប៉ុណ្ណោះ ដែលសាស្ត្រាចារ្យមិនបានខ្ពស់ស្ថិតក្នុងកម្រិតបង្គួរ(Mean<៣.៥0)ដូចជាចំណុចទី៧ បង្កើតសកម្មភាពរៀនរបស់អ្នកសិក្សាសំបូរបែបមធ្យម (Mean=៣.១៦) ចំណុចទី១ (Mean=៣.១៨) ។ តាមរយៈចំណុចខាងលើបានបង្ហាញថា សាស្ត្រាចារ្យដែលជា គ្រូឧទ្ទេសក្នុងកម្មវិធីពន្លឿន នៅវិទ្យាស្ថានជាតិអប់រំ សុទ្ធតែជាគ្រូឧទ្ទេសដែលមានគុណវុឌ្ឍិ ស្តង់ដាគ្រូបង្រៀន មានទាំងសមត្ថភាពចំណេះដឹង និងសមត្ថភាពការផ្ទេរចំណេះដឹង បានកម្រិតខ្ពស់នៅឡើយមានចំណុចតិចតួចបំផុតត្រង់ចំណុចទី៧ ការបង្កើតសកម្មភាពសិក្សារបស់សិស្សមិនទាន់សំបូរបែបខ្លាំងខ្លាប៉ុន្មានទេគឺ បានម្រិតខ្ពស់បង្គួរ (Mean = ៣.១៦) គម្លាតស្តង់ដា(SD = 0.៨៨)។

